ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែកក្កដា លេខ ៧

ព.ស. ២៤៩៧ – គ.ស. ១៩៥៤

បណ្ណាល័យ
LIBRARY
HIST INSTITUTE

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា . បញ្ជីរឿង ទំព័រ

— មគ្គញាតកថា .............................. ព្រះមហា ជា- ឆាយ ....... ៤៨៣
— បញ្ញាសជាតក ភាគទី ២ (តមក) . ... បណ្ឌិតមហា ឈឹម- ស៊ុម .... ៤៩៧

ផ្នែកអក្សរសាស្ត្រ

— រឿងសៅរ៍សោយ (តមក) ...... .. ព្រះមហាឧត្តមវិជ្ជា ប៊ុង- ប៉ម .. ៥១២
— រឿងសាមកុក (តមក) ........... ឧកញ៉ា នូ- កន ......... ៥១៨
— ឆាលៈនិងទមយន្តី (តមក) ........ អ្នកស្រី ស៊ុន- សារិយ៉ាន់ .... ៥២៤
— ដំណើរអស្ចារ្យនៃលោក វ៉ាស្ញូបឺយូយេ
(ត- ចប់) ................ លោកភ៉យ- ប៊ុក ក្រុមការ .... ៥៣១
— ដំណឹងតាមខ្យល់ក្នុងកន្ទារៈ (តមក) .... លោកផេង- ជ្រីវ ......... ៥៤៤

កំណត់ទីនប្រវត្តិការណ៍

— ពិធីបុណ្យព្រហ្មទាន ................ ពុទ្ធសាសនបណ្ឌិត្យ ........ ៥៤៨

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES


PARTIE RELIGIEUSE: Page

— Mattannutakatha . . . . . . *Brah maha CHEA-CHHAY* . . . 483

— Pannasajataka vol-II (suite) . *M. CHHIM-SOUM* . . . . . . 497

PARTIE LITTERAIRE:

— Le « SAU-SOY » ou l'influence saturnienne (suite) . . . . . *Brah Maha PEUNG-PAM* . . . 512

— Histoire de Samkok (suite) . . *Oknha NOU-KAN* . . . . . . 518

— Nala et Damayanti (suite) . . *Mme SRIN-SARIS-YANN* . . . 524

— Le voyage extraordinaire de Vasio bioyé (suite et fin) . . *M. RAY-BUC* . . . . . . . . . 531

— Le souffle du désert (suite) . *M. PHENG-CHRIV* . . . . . . 544

NOTES ET CHRONIQUES:

— Distribution des prix à l'Ecole Supérieure de Pali . . . . . *INSTITUT-BOUDDHIQUE* . . . 548


Prix d'abonnement annuel (comprenant 12 numéros) 200$00

## មត្តញ្ញុតាកថា

## ព្រះមហា ជា-ឆាយ វត្តឧណ្ណាលោម

រៀបរៀង

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព) ។

ថ្ងៃនេះជាថ្ងៃឧបោសថកាល, ពួកពុទ្ធបរិស័ទខ្លះបានសមាទានឧបោសថសីលតាំងពីបុព្វណ្ហសម័យ ។ ពេលនេះជាធម្មស្សវនកាលត្រូវតាមសណ្ដាប់ប្រពៃណីពីបុរាណសម័យ នៃពុទ្ធមាមកជនរៀងពបមក ។ អាត្មាភាពបានទទួលភារៈមកសំដែងព្រះធម៌តាមសមគួរដល់កាលវេលា ។ សូមសំដែងអំពីមត្តញ្ញុតាកថា តាមន័យពុទ្ធភាសិតមួយបាទថា :

## មត្តញ្ញុតា សទា សាធុ

" ការៈនៃបុគ្គលអ្នកស្គាល់ប្រមាណ រមែងញុំាងប្រយោជន៍ឲ្យសម្រេចសព្វៗ កាល" ។

ពុទ្ធភាសិតនេះ ព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់សរសើរបុគ្គលអ្នកស្គាល់ប្រមាណ ថាជាអ្នកអាចធ្វើប្រយោជន៍ឲ្យសម្រេចបានគ្រប់កាល ។

សូមអធិប្បាយសេចក្ដីនៃពុទ្ធភាសិតនេះដូចសេចក្ដីតទៅនេះ :

**មត្តញ្ញុតា** ប្រែថា " ភាពនៃបុគ្គលអ្នកស្គាល់នូវប្រមាណ " គឺ ស្គាល់ថា ធ្វើយ៉ាងនេះសម, យ៉ាងនេះល្អ, យ៉ាងនេះចុះរបៀប, ត្រូវទំនងសមតាមកាលៈទេសៈ, កាលបើធ្វើយ៉ាងនេះទៅ រមែងបានសម្រេចប្រយោជន៍យ៉ាងនោះ ជាដើម ។ ការស្គាល់ប្រមាណនេះ មានទំនងគួរនឹងពណ៌នាបានច្រើនន័យ តែបើនឹងរួបរួមជាគោលនៃសេចក្ដីអធិប្បាយ មានតែ ៥ ប្រការ ដូច្នេះ គឺ :

១ – ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ
២ – ការដឹងប្រមាណក្នុងករណីយកិច្ច
៣ – ការដឹងប្រមាណក្នុងការថែទាំខ្លួន
៤ – ការដឹងប្រមាណក្នុងបុគ្គល
៥ – ការដឹងប្រមាណក្នុងធម៌ ។

## ទី ១ – ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ

ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិនេះ ចែកចេញជា ៣ ប្រការតទៅទៀត គឺស្គាល់ប្រមាណក្នុងការស្វែងរក ១ ស្គាល់ប្រមាណក្នុងការថែរក្សា ១ ស្គាល់ប្រមាណក្នុងការបរិភោគប្រើប្រាស់ ១ ។

ការចេះលៃលករកឧបាយស្វែងរកទ្រព្យសម្បត្តិ ឲ្យត្រឹមត្រូវតាមគន្លងធម៌ គឺវៀរចាកជំនួញ ៥ ប្រការ, មិនស្វែងរកដោយអាការកុហក

ករកូតឆបោកបំបាត់ប្រវញ្ចទ្រព្យរបស់អ្នកដទៃ មិនរំពៃគយគន់សំឡឹងសំឡក់លួចឆក់របជាន់ដណ្តើមយកកោតទ្រព្យអ្នកដទៃ ដោយកិច្ចកលពោរកម្ម, មិនបន្លំដោយក្អែកដញ្ជង តែកៀសដោយរង្វាល់ នាឡិ តៅ កន្តាំង បំបិទបំបាំងតែលៃលកឲ្យតែបានចំណេញ ដោយឧបាយកលទុច្ចរិត ៗ ទាំងត្រូវវៀរចាកស្ថាន ៤ យ៉ាងទៀត គឺវៀរមិនលំអៀងព្រោះសេចក្តីគាប់ចិត្ត សេចក្តីស្រឡាញ់ ១ មិនលំអៀងព្រោះសេចក្តីខេរខឹង ឬសេចក្តីស្អប់ ១ មិនលំអៀងព្រោះសេចក្តីល្ងង់ខ្លៅ មិនដឹងខុសត្រូវ ១ មិនលំអៀងព្រោះខ្លាចអំណាច ១ ហើយមិនប្រព្រឹត្តស៊ីសំណូកសូកអង្វររសង្កត់សង្កិនយកផលប្រយោជន៍ឡើយ ព្រោះសុទ្ធតែជាការស្វែងរកមិនសម មិនល្អ មិនត្រូវទំនងទេ ជាការស្វែងរកខុសចាកគន្លងធម៌ដោយពិតប្រាកដ ៗ ការស្វែងរកដោយឧបាយទុច្ចរិតព្រះពុទ្ធជាម្ចាស់ទ្រង់ហាម ព្រោះជាហេតុនាំឲ្យមានសេចក្តីក្តៅក្រហាយទាំងនាំឲ្យជួបប្រទះនឹងទុក្ខទោសគ្រោះថ្នាក់ច្រើនប្រការផង ឈ្មោះថាស្វែងរកសេចក្តីទុក្ខមកឲ្យខ្លួននឹងអ្នកដទៃ នាំឲ្យមានសេចក្តីវិនាសក្នុងលោកទាំងពីរ ៗ ហេតុនេះ សាធុជនគួរតែគេចវៀរចៀសវាងឲ្យផុតអំពីការស្វែងរកមិនប្រកបដោយធម៌ ហើយស្វែងរកដោយឧបាយប្រកបដោយធម៌វិញ ទើបជាហេតុនាំឲ្យត្រជាក់ចិត្តខ្លួននឹងអ្នកដទៃ, ទ្រព្យសម្បត្តិដែលរកបានមកដោយសុចរិត ជាសម្បត្តិនិត្យនៅចំរុងចំរើនឡើង

តាមលំដាប់ ៗ កាលបើស្វែងរកទ្រព្យសម្បត្តិ បានមកដោយយុត្តិធម៌ត្រឹមត្រូវហើយ គួរស្គាល់ប្រមាណកុ្នងការថែរក្សាទ្រព្យនោះថែមទៀត គឺត្រូវចេះរក្សាកុំឲ្យខូចអន្តរាយ ដោយភ័យផ្សេង ៗ គឺពជភ័យ, ចោរភ័យ, អគ្គិភ័យ, ឧទកភ័យ, និងអ្នករួមមត្រិកជាមួយគ្នា ដោយបានគិតប្រុងជានិច្ចថា " អាត្មាអញគិតធ្វើដូចម្តេចហ្ន៎ ដើម្បីកុំឲ្យពជការរឹបជាន់យកទ្រព្យសម្បត្តិ កុំឲ្យពជការលក់ពន្ធ័យទោសបាន, កុំឲ្យចោរលួចប្លន់ កុំឲ្យមានអាសន្នដោយភ្លើងឆេះ, កុំឲ្យទឹកលិច, កុំឲ្យមនុស្សអ្នករួមមត្រិកជាមួយដែលមិនគាប់ចិត្តនិងគ្នាដណ្តើមយកទៅបាន" ។ ព្រោះថាទ្រព្យសម្បត្តិដែលរកបានមកហើយ បើបណ្តោតបណ្តោយធ្វេសប្រហែសនឹងវិនាសបាត់ទៅវិញ ដោយភ័យផ្សេង ៗ មានពជភ័យជាដើមនោះនាំឲ្យបង់កំឡាំងខូចខាតពេលវេលាដែលខំរកខំធ្វើមក ចួនកាលនាំឲ្យបង់ខាតទ្រព្យធនជាទុនដើម ដោយតាមរករបស់ដែលបាត់ទៅនោះទ្វេភាគឡើងទៀតក៏សឹងមាន ។ ហេតុនេះ បុគ្គលជាម្ចាស់ទ្រព្យគួរតែប្រយ័ត្នកុ្នងការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិឲ្យម៉ឺងម៉ាត់ ទើបបាត់ថាជាអ្នកស្គាល់ប្រមាណកុ្នងការថែរក្សា ។ ដើម្បីនឹងថែរក្សាទ្រព្យសម្បត្តិឲ្យបានឋិតថេរចិរកាលទៅនោះ ត្រូវដើរនឹងវិធីរក្សាដូចតទៅនេះ :

១ — ចេះស្វែងរករបស់ដែលបាត់

២ - . ចេះជួសជុលរបស់ដែលចាស់គ្រាំគ្រា

៣ - ចេះប្រើប្រាស់ឲ្យល្មមដល់ប្រមាណ

៤ - មិនតាំងបុរស ឬស្ត្រីទ្រុស្តសីលជាធំ ។

មែនពិត, ធម្មតាទ្រព្យសម្បត្តិដែលគង់នៅ ឬ នឹងចំរើនតទៅទៀតបាននោះ ក៏ពីព្រោះតែអ្នកម្ចាស់ទ្រព្យចេះថែរក្សា ចេះចាយចេះប្រើប្រាស់ ។

បុគ្គលដែលស្គាល់ប្រមាណក្នុងការប្រើប្រាស់ ចាយវាយទ្រព្យសម្បត្តិតាមកម្លាំងធនធានរបស់ខ្លួន ដឹងអស់ដឹងគង់ដឹងបង់ដឹងបាត់, មិនចាយខ្ជះខ្ជាយគោកោវឥតសណ្ដាប់ធ្នាប់ មិនបណ្ដោយឲ្យសម្បត្តិទ្រព្យវិនាសអន្តរាយដោយល្បែងពាលា ល្បែងស្រី ល្បែងស្រា កញ្ឆា អាភៀន ឬញៀនញ៉ាំជាប់ចិត្តនឹងល្បែងក្បាលផ្សេងៗ មានបៀ ប៉ោ ផ្ទួ អាប៉ោងជាដើម ទើបចាត់ថាជាអ្នកស្គាល់ប្រមាណក្នុងការប្រើប្រាស់ចាយវាយ ។ ម្យ៉ាងទៀត ត្រូវចេះទុកដាក់ទ្រព្យរបស់ឲ្យមានរបៀបរៀបរយល្អ កុំចោលរាត់រាយ ដូចអ្នកខ្លះមានផ្ទះធំទូលាយល្អពេក តែមិនចេះរៀបចំទុកដាក់ឲ្យល្អស្អាតបាត ចេះតែគ្រាត់គ្រាវែងរាយប៉ាយពេញតែផ្ទះសម្បែង ម៉្លោះហើយទៅជាចង្អៀតចង្អល់ស្មុកស្មាញ មិនល្អមើលទៅវិញ ។ ត្រូវចេះថែរបស់ឲ្យល្អ គឺត្រូវដឹងថា របស់នេះតូច, ធំ, ក្រាស់, ស្តើង, ដាច់, ផុយ, តិច, ច្រើនជាដើម ហើយប្រើយ៉ាងណាឲ្យតែខាងបានល្អសមរម្យ មិនធ្គងនឹងភ្នែកអ្នកផង ត្រូវចេះលៃលកកែ។ ចាយជួសជុល

តែកុនប៉ះប៉ុន ទ្រព្យរបស់ដែលបាក់បែក ឬប្រឡាក់ប្រឡូស បេះដូសដុល ដុសខាត់សំអាតឲ្យល្អជាប្រក្រតី, យ៉ាងនេះទើបបាត់ថាជាអ្នកស្គាល់ប្រមាណក្នុងការប្រើប្រាស់ ។

ន័យមួយទៀត បុគ្គលអ្នកដឹងប្រមាណក្នុងទ្រព្យសម្បត្តិដែលស្វែងរក ថែរក្សា ប្រើប្រាស់ទ្រព្យសម្បត្តិឲ្យត្រឹមត្រូវតាមធម៌ដូចពណ៌នាមកនេះ ឈ្មោះថាជាអ្នកញ៉ាំងប្រយោជន៍ឲ្យសម្រេចបានគ្រប់កាល ឈ្មោះថាជាអ្នកមានសេចក្ដីសុខច្រើនប្រការណាស់ ព្រោះទ្រព្យសម្បត្តិនោះអាចញ៉ាំងបុគ្គលជាម្ចាស់ទ្រព្យឲ្យសម្រេចប្រយោជន៍ដូចតទៅនេះ

១ – អ្នកមានទ្រព្យសម្បត្តិ តែងចិញ្ចឹមខ្លួន និងក្រុមគ្រួសារគឺ មាតាបិតា បុត្រធីតា ទាសកម្មករ ឲ្យជាសុខទៅបាន ។

២ – អ្នកមានទ្រព្យសម្បត្តិ អាចបង់ម៉ែត្រមេត្រីនឹងអ្នកដែលរួមខាងបានតាមត្រូវការ ។

៣ – អ្នកមានទ្រព្យសម្បត្តិ អាចបំបាត់ភ័យអន្តរាយ៖បទ្រពចង្រៃដែលកើតអំពីហេតុផ្សេងៗ បាន ។

៤ – អ្នកមានទ្រព្យសម្បត្តិ អាចធ្វើនូវពលិកម្ម ៥ ប្រការ គឺ:

ក) ញាតិពលិ ការសង្គ្រោះញាតិ

ខ) អតិថិពលិ ការទទួលភ្ញៀវ

គ) បុព្វបេតពលិ ការធ្វើបុណ្យឧទ្ទិសផលជូនដល់បុព្វបុរសដែលចែកឋានបាត់ទៅហើយ

ឃ) រាជពលិ ការបង់ពន្ធដារស្ពួយសារអាករជាប្រយោជន៍ដែនដី

ង) ទេវតាពលិ ការធ្វើបុណ្យឧទ្ទិសផលថ្វាយទេវតា ។

៥ – អ្នកមានទ្រព្យសម្បត្តិ អាចបរិច្ចាគទ្រព្យរបស់ខ្លួន ឲ្យជាទានដល់សមណព្រាហ្មណ៍អ្នកប្រព្រឹត្តត្រឹមត្រូវបានតាមប្រាថ្នា ឬក៏អាចកសាងសាលាទានជាសាធារណៈ ឬកុដិ វិហារ សាលា ជាសង្ឃទានប្រគេនសង្ឃ អ្នកប្រកបកិច្ចក្នុងព្រះពុទ្ធសាសនា ឬសាងសាលារៀន មន្ទីរពេទ្យ ទំនុកបំរុងការរៀនសូត្រ, ទំនុកបំរុងខាងការព្យាបាលរោគបានដោយសេរីនិងសេចក្តីត្រូវការ ។

រួមការដឹងប្រមាណដូចបានអធិប្បាយមកនេះ ឈ្មោះថាការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ ។

## ទី ២ – ការដឹងប្រមាណក្នុងករណីយកិច្ច

កិច្ចការដែលយើងត្រូវធ្វើ ហៅថា ករណីយកិច្ច, ធម្មតាកិច្ចការក្នុងលោកទាំងអស់ សុទ្ធសឹងតែមានសភាពប្លែក ៗ ពីគ្នា គឺកិច្ចការខ្លះក្រលំបាកធ្វើ, កិច្ចការខ្លះងាយស្រួល ស្រណុកធ្វើ, កិច្ចការខ្លះច្រើន

ខ្វះតិច, ខ្វះធ្វើយូរ ខ្វះធ្វើឆាប់; តែបើរួមឲ្យខ្លីមក្មមានតែត្រឹម ២ យ៉ាងគឺ កិច្ចការដែលត្រូវធ្វើដោយប្រាជ្ញា ១ កិច្ចការដែលត្រូវធ្វើដោយកម្លាំង ១ ។ ការសិក្សារៀនសូត្រនូវចំណេះវិជ្ជា អក្សរសាស្ត្រ ចក្ខុពួធលេខ បរមត្ថ-វិជ្ជា ធម៌វិន័យត្រៃសិក្ខា ជាដើម ហៅថាកិច្ចការដែលត្រូវធ្វើដោយប្រាជ្ញា ព្រោះជាកិច្ចដែលយើងត្រូវប្រើគំនិតរិះពិចារណា ឲ្យយល់ចូលចិត្តពិតប្រាកដទើបធ្វើទៅបាន ។ កិច្ចការហត្ថកម្មសម្រាប់អ្នកស្រែចំការ ជាងឈើ ជាងកំបោរ ឬការដែលត្រូវលើកលីពុនជញ្ជូនរែកសែងជាដើម ឈ្មោះថាកិច្ចការត្រូវធ្វើដោយកម្លាំង ។

ការដឹងប្រមាណ គឺស្គាល់ថា កិច្ចការនេះត្រូវធ្វើយ៉ាងនោះ, កិច្ចការនោះ ត្រូវធ្វើយ៉ាងនេះ, កិច្ចនេះគួរធ្វើ កិច្ចនោះមិនគួរធ្វើ, អំពើនេះធ្វើទៅនាំឲ្យចំរើន, អំពើនោះធ្វើទៅនាំឲ្យវិនាសហិនហោចប្រយោជន៍ខ្លួនទីងអ្នងដទៃ; យ៉ាងនេះជាដើម ហៅថាស្គាល់ប្រមាណកងកិច្ចការ ។ មែនពិត, កិច្ចការណាក៏ដោយ ដែលជាកិច្ចត្រូវធ្វើនោះ បុគ្គលត្រូវតែពិចារណាឲ្យជាក់ច្បាស់ចូលចិត្តស៊ប់សិន សឹមធ្វើទើបប្រសើរ ព្រោះថាកិច្ចការដែលបុគ្គលធ្វើច្រឡំច្រឡូសហួសទៅហើយ ហើយកាយកាចចិត្ត រមែងជិតជាប់ស្អិតនៅប្រាកដ មិនងាយនឹងកែប្រែបានឡើយ ប្រៀបដូចជាឆ្នាំងដីដែលបែកហើយមិនដែលផ្សារភ្ជាប់វិញបានទេ បើទុកជាផ្សារបាន ក៏មិនជាប់មាំល្អដូចដើម ។ កិច្ចការណាដែល

បុគ្គលធ្វើទៅហើយ ក្តៅក្រហាយតាមក្រោយ នាំឲ្យខូចខាតប្រយោជន៍ខ្លួនទាំងអ្នកឯទៀត នាំឲ្យបង្អៀតបង្អល់ដល់ចិត្តគំនិតអញ្ញាស្រ័យអ្នកដទៃ បុគ្គលមិនគប្បីធ្វើកិច្ចការនោះឡើយ, សមដូចជាពុទ្ធភាសិតថា អកតំ ទុក្កដំ សេយ្យោ "អំពើអាក្រក់ បុគ្គលកុំធ្វើ ល្អជាង" ។ បុគ្គលអ្នកធ្វើអំពើអាក្រក់មិនងាយបានសេចក្តីសុខកាយសប្បាយចិត្តទេ ។ បុគ្គលអ្នកស្គាល់ប្រមាណក្នុងកិច្ចការ ដែលខ្លួនត្រូវធ្វើដូចពណ៌នាមកនេះ ហៅថា ដឹងប្រមាណក្នុងករណីយកិច្ច ។

## ទី ៣.— ការដឹងប្រមាណក្នុងការថែរក្សាខ្លួន

ខ្លួនជាទីស្រឡាញ់ពេញចិត្តរបស់ជនគ្រប់គ្នាទាំងអស់ បានជាជនទាំងនោះខំថ្នាក់ថ្នមថែទាំរក្សាខ្លួន ឲ្យបានសេចក្តីសុខដោយឧបាយផ្សេងៗគ្នា, អ្នកខ្លះក៏បេះរក្សាខ្លួនឲ្យបានសុខភាពគ្រាន់បើ, អ្នកខ្លះក៏ត្រឡប់ជាផ្ទុយនឹងបំណងដើមទៅវិញ ។ ព្រះពុទ្ធជាបរមគ្រូទ្រង់ត្រាស់ប្រដៅឲ្យថែរក្សាខ្លួនដោយវិធីសំអាតភូមិភាគ គេហដ្ឋាន សំអាតគ្រឿងប្រើប្រាស់ សំអាតគ្រឿងស្លៀកពាក់ សំអាតគ្រឿងផឹកនឹងភោជន៍ភ័ស្តុចំណីអាហារ សំអាតសរីរាវយវៈរាងកាយឲ្យស្អាតល្អ ព្រោះថាកាលបើទីលំនៅជាដើមមិនស្អាតល្អហើយ ជាហេតុនាំឲ្យរូបរាងកាយរបស់យើងដែលអាស្រ័យនូវគ្រឿងមិនស្អាតមានរោគផ្សេងៗ, កាលបើរូប

ពង្សកាយមានរោគហើយ ចិត្តដែលអាស្រ័យនៅក្នុងរូបកាយ ធ្វើម្ដេចនឹងប្រព្រឹត្តទៅដោយស្រួលបាន? កាលបើចិត្តមិនស្រួលហើយ គំនិតប្រាជ្ញាធ្វើម្ដេចនឹងដុះដាលចំរើនឡើងបាន? កាលបើគំនិតប្រាជ្ញាមិនចំរើនលូតលាស់ក៏ស្ងាន់ហើយ ប្រយោជន៍ដែលយើងត្រូវការចង់បានក្នុងបច្ចុប្បន្ននេះ នឹងលោកខាងមុខ ធ្វើម្ដេចនឹងសម្រេចតាមប្រាថ្នាទៅបាន? ហេតុនេះគួរយល់ថា បណ្ដារោគទាំងអស់សុទ្ធតែជាសត្រូវជាបច្ចាមិត្រជាអ្នកបំផ្លាញនូវប្រយោជន៍នៃអស់យើងពល់គ្នា ព្រោះសេចក្ដីពិតថា អ្នកណាមួយ ទោះជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភក្ដី ជាអ្នកប្រាជ្ញក្ដី ជានាម៉ឺន ឬព្រស្ដ្រប្រជាក្ដី កាលបើត្រូវរោគចូលមកលុកលុយជិះជាន់ក្នុងរូបកាយហើយក៏ត្រឡប់ជាមានអានុភាពតិច ប្រើការមិនកើតទាំងអស់ ព្រោះតាញអំណាចរោគ ។ ហេតុដូច្នេះ គួរយើងខំខុសប្រាហ៍សំអាតទីលំនៅជាដើម ដើម្បីការពារបិទផ្លូវកុំឲ្យរោគកើតឡើងបាន ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សរសើរណាស់ នូវបុគ្គលដែលចេះថែរក្សាពង្សកាយ ថានាំឲ្យបានសេចក្ដីសុខសប្បាយ មានអាយុយឺនយូរ, ទ្រង់ត្រាស់សំដែងថា សណិកំ ជីវតិ អាយុំ បាល្យំ "អាយុដែលបុគ្គលរក្សា រមែងចាស់គ្រាំគ្រា ទៅសន្សឹមៗ បន្តិចម្ដងៗ" ។

រួមសេចក្ដីដែលអធិប្បាយមកនេះហៅថា ដឹងប្រមាណក្នុងការថែរក្សាខ្លួន ៕

## ទី ៤ — ការដឹងប្រមាណក្នុងបុគ្គល

ការដឹងប្រមាណក្នុងបុគ្គល សំដៅយកការចេះលៃលកតម្រូវអធ្យាស្រ័យនៃគ្នានឹងគ្នា ដែលនៅក្នុងសង្គមជាមួយដើម្បីនឹងរក្សាសេចក្ដីសុខឲ្យកើតមានសព្វខ្លួន ព្រោះមនុស្សយើងដែលកើតឡើងក្នុងលោក មានសន្ដានមិនដូចគ្នាទាំងអស់ទេ មានមុខក្រសួងបុណ្យសក្ដិខ្ពស់ទាប មានទ្រព្យសម្បត្តិតិចច្រើន មានការកាន់ទំនៀមទំលាប់ផ្សេងៗ ដោយឡែកៗពីគ្នា ទើបព្រះសាស្ដាទ្រង់ត្រាស់ប្រដៅឲ្យដឹងប្រមាណក្នុងបុគ្គល ដូចសេចក្ដីពន្យល់តទៅនេះ ៖

១ – ត្រូវឲ្យមានសេចក្ដីស្មោះត្រង់រកគ្នា ចេះសង្គ្រោះគ្នាទៅវិញទៅមកតាមថ្នាក់តាមជាន់ គឺមាតាបិតានឹងបុត្រធីតា, គ្រូអាចារ្យនឹងសិស្ស, ស្វាមីនឹងភរិយា, មិត្តសម្លាញ់នឹងមិត្តសម្លាញ់ផងគ្នា, ចៅហ្វាយនាយនឹងជនអ្នកនៅក្រោមបង្គាប់, បព្វជិតនឹងគ្រហស្ថ ត្រូវសំដែងសេចក្ដីស្មោះត្រង់ទៅវិញទៅមក កុំកាន់កិរិយាខ្ទង់សត្រូវរកគ្នា ។

២ – ត្រូវចេះទប់ចិត្ត ទប់សំដី ចេះបន្ទន់កាយឱនលំទោនរកគ្នា ចេះទុកខ្លួនក្នុងវេលាដែលឧបសគ្គណាមួយចូលមកញាំញី មិនឲ្យកើតសេចក្ដីក្រោធខឹង នាំឲ្យឈ្លោះទាស់ទែងខ្វែងគំនិតគ្នា ។

៣ – បើមានសេចក្ដីក្រោធកើតឡើង ត្រូវចេះបន្ទោរបន្ទយកំហឹងនោះឲ្យរលស់ស្រាកស្រុតទៅវិញ, ត្រូវចេះលៃលករកឧបាយដើម្បី

រំលត់កំហឹង គួរកុំព្យាបាទ ចងអាឃាតគុំគួនគ្នា ព្រោះនឹងនាំឲ្យមានពៀរនឹងគ្នាទៅថ្ងៃមុខ ។

៤ – ត្រូវចេះរំលែកចែកចាយ បំណាយធនធានទ្រព្យអាហារចំណី គ្រឿងបរិភោគ ឧបភោគ ឲ្យដល់គ្នីគ្នា ។ –

ការដឹងប្រមាណដូចបានពោលមកនេះ ហៅថា ដឹងប្រមាណក្នុងបុគ្គល ។

## ទី ៥ – ការដឹងប្រមាណក្នុងធម៌

ការចេះលៃលកទន្ទេញស្វាធ្យាយ សង្កេតពិនិត្យពិនិច្ឆ័យនូវសេចក្ដីធម៌អាថ៌ណាមួយ ឲ្យយល់ចូលចិត្តជាក់ច្បាស់ ចេះចាំប្រាកដស្ទាត់ជំនាញ ឬក៏សេចក្ដីឈ្លាសវៃក្នុងការបង្ហាត់បង្រៀនប្រៀនប្រដៅណែនាំពន្យល់ធម៌តាមកាលគួរ តាមដំណើរបរិស័ទតិចច្រើន ព្រមទាំងការយល់ទំនងកម្រងធម៌ថា ធម៌នេះត្រូវលះបង់ ធម៌នេះត្រូវចំរើន ឬយល់ទំនងនៃសេចក្ដីប្រតិបត្តិ ដូចដឹងថា ទានត្រូវបរិច្ចាគយ៉ាងនេះទើបមានផលច្រើន, សីលត្រូវរក្សាយ៉ាងដូច្នេះ ទើបបរិសុទ្ធ, ភាវនាត្រូវចំរើនតាមរបៀបនេះ ទើបសម្រេចគុណវិសេស; ដូច្នេះជាដើម ហៅថា ស្គាល់ប្រមាណក្នុងធម៌ ។ បុគ្គលអ្នកស្គាល់ប្រមាណក្នុងធម៌ហើយប្រតិបត្តិតាមធម៌ រមែងបានទទួលកម្រៃផលពីព្រះធម៌វិញ, ដូចពុទ្ធភាសិតថា ធម្មោ ហវេ រក្ខតិ

ធម្មចារិំ ឆត្តំ មហន្តំ វិយ វស្សកាលេ "ធម៌តែងអភិបាលរក្សាបុគ្គលអ្នកប្រព្រឹត្តប្រតិបត្តិតាមធម៌ ដូចឆត្រធំសម្រាប់បាំងការពារមិនឲ្យភ្លៀងទទឹក" ។ ន ទុគ្គតឹ គច្ឆតិ ធម្មចារី "បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ" ។ ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច "បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងសម្រេចឥរិយាបថទាំង ៤ គឺដេក ដើរ ឈរ អង្គុយ ជាសុខក្នុងលោកនេះ និងលោកខាងមុខ" ។

រួបរួមការដឹងប្រមាណទាំង ៥ ប្រការ ដូចបានពណ៌នាមកនេះ ហៅថា មត្តញ្ញុតា "ភាពនៃបុគ្គលអ្នកស្គាល់ប្រមាណ" ។ បុគ្គលអ្នកដឹងប្រមាណ ដូចបានពណ៌នាមកដោយសង្ខេប ៗ នេះ រមែងញុំាងប្រយោជន៍គ្រប់យ៉ាង ឲ្យសម្រេចបានគ្រប់កាល ដូចពុទ្ធភាសិតដែលបានពោលខាងដើមហើយ ថា មត្តញ្ញុតា សទា សាធុ ។

អាត្មាភាពសំដែងធម៌ទេសនាមកនេះ សមគួរដល់កាលវេលាតែប៉ុណ្ណេះ ។ សូមឲ្យពុទ្ធបរិស័ទសប្បុរសទាំងឡាយបានសម្រេចឥដ្ឋមនុញ្ញផលវិបុលសុខគ្រប់ប្រការ! ។

ធម្មទេសនានុភាវេន សុខិតា ហោន្តុ បាណិនោ
ទីសុ អត្ថេសុ តិដ្ឋន្តុ សហ សព្វេហិ ញាតិភិ

ដោយអានុភាពនៃព្រះធម៌ទេសនានេះ សូមឲ្យសត្វទាំងឡាយបាន សេចក្ដីសុខគ្រប់ប្រការ! សូមឲ្យតាំងនៅក្នុងប្រយោជន៍ទាំងពីរប្រការ គឺ ប្រយោជន៍ក្នុងលោកនេះ នឹងបរលោក ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា!

រតនត្តយតេជេន សកលលោកវាសិនោ
វុឌ្ឍឹ វិរុឡ្ហឹ បប្បោន្តុ សន្តិភាវញ្ច នាញ្ញថា ។

ដោយតេជានុភាពនៃព្រះរតនត្រៃ គឺព្រះពុទ្ធ ព្រះធម៌នឹងព្រះសង្ឃ សូមឲ្យប្រជាជនទាំងឡាយដែលអាស្រ័យនៅក្នុងសកលលោក បានដល់នូវការលូតលាស់ដុះចំរើន នឹងសន្តិភាព កុំបីឃ្លាតក្លាយជាបការៈដទៃឡើយ! ។

---

## ធម៌នៃអ្នកម្ចាស់ផ្ទះដែលត្រូវប្រតិបត្តិទៅរកភ្ញៀវ

ជូរមក! មកណេះ! អញ្ជើញអង្គុយលើអាសនៈនេះ! ហេតុអ្វីក៏ខានអញ្ជើញមកលេងយូរម្ល៉េះ? អ្នកសុខសប្បាយជានាទេឬ? ហ្អឺអ្នកខ្ពិលណាស់តើ! សូមជូនពរអ្នកឲ្យសុខសប្បាយ! ខ្ញុំមានចិត្តរីករាយសប្បាយណាស់បានឃើញអ្នកមកលេង! ។ នេះជាសិរីនៃលោកសប្បុរសទាំងឡាយ ដែលលោកឃើញនរជនណាមួយមកដល់ផ្ទះ បើទុកជាជននោះជាជនថោកទាបក៏ដោយ លោកតែងតែនិយាយដូច្នេះជាប ។ នេះជាធម៌នៃម្ចាស់ផ្ទះទាំងឡាយ ជាធម៌ងាយសោះ ហើយអាចប្រគល់ស្ពាទស្ទូតិឲ្យទៀតផង ។

បញ្ញាគន្ត្រ:

# បញ្ញាសជាតក

## ភាគទី ២

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាបព្វជិត ពី ព. ស. ២៤៨៦, គ. ស. ១៩៤៣

(តមក)

---

## សុកមិត្តជាតក ទី ៩

(និយាយអំពីដំណើរព្រាត់ប្រាស ព្រោះមាះពៀរដោយយកកូនសត្វ)

លោកអាចារ្យ ឈឹម - ស៊ុម ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

---

អវិកាសិ តុវំ ទេវាតិ ឥទំ ធម្មទេសនំ សត្ថា ជេតវនេ វិហរន្តោ ទេវទត្តស្ស អកតញ្ញុតំ អារព្ភ កថេសិ ។ កាលសម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់គង់នៅវត្តជេតពនសុគន្ធកុដីសិរីមហាវិហារ ទ្រង់ប្រារព្ធសេចក្តីអកតញ្ញូរបស់ទេវទត្ត ហើយសំដែងព្រះធម៌ទេសនា មានបទព្រះបាលីថា អវិកាសិ តុវំ ទេវ ដូច្នេះជាដើម ។

សេចក្តីដំណាលថា សម័យថ្ងៃមួយនោះ ភិក្ខុទាំងឡាយកំពុងប្រជុំនិយាយគ្នាអំពីសេចក្តីអកតញ្ញូរបស់ទេវទត្ត ព្វតែស្ងួរស័ព្ទមាត់ទ្រហឹងក្នុង

សាលាធម្មសភា; ដ្បិតជាសម្តេចព្រះបរមសាស្តា ទ្រង់ពុទ្ធដំណើរចូលមក ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ, អម្បាញ់មិញនេះ អ្នកទាំងឡាយប្រជុំនិយាយគ្នាពីរឿងអ្វី?" ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស, ខ្ញុំព្រះអង្គទាំងឡាយប្រជុំនិយាយពីរឿងទេវទត្តដែលមានសេចក្តីអកតញ្ញូ" ។ សម្តេចព្រះបរមគ្រូទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ, ទេវទត្តជាមនុស្សអកតញ្ញូមិនត្រឹមតែឥឡូវនេះទេ, ពីដើមមកក៏ជាបុគ្គលអកតញ្ញូចំពោះតថាគតដែរ"; ទ្រង់ត្រាស់តែប៉ុណ្ណោះហើយក៏ទ្រង់គង់ស្ងៀម ពុំមានព្រះពុទ្ធដីកាថាដូចម្តេចទៅទៀតសោះ, ត្រាតែភិក្ខុទាំងនោះអារាធនា ទើបទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា ៖

អតីតេ កិរ ភិក្ខវេ បព្បាកនគរេ សុភមិត្តោ នាម រាជា រជ្ជំ ការេសិ ម្នាលភិក្ខុទាំងឡាយ, កាលពីព្រេងនាយ មានព្រះបរមក្សត្រមួយព្រះអង្គទ្រង់ព្រះនាម ព្រះបាទសុភមិត្ត សោយរាជសម្បត្តិក្នុងនគរបព្បាក, ទ្រង់មានព្រះអនុជមួយព្រះអង្គទ្រង់ព្រះនាម អសុភមិត្តជាឧបរាជ ។ ព្រះអង្គមានព្រះរាជទេវីព្រះនាម នាងកេសិនី, មានព្រះរាជបុត្រាពីរព្រះអង្គគឺព្រះរាជបុត្រច្បងព្រះនាម ជេយ្យសេនកុមារ ព្រះរាជបុត្រប្អូនព្រះនាម ជេយ្យទត្តកុមារ ។

ចំណេរតមកខាងក្រោយ អសុភមិត្តជាឧបរាជ មានគំនិតគិតក្បត់ថា "កាលបើព្រះរៀមរបស់អញនៅក្នុងរាជសម្បត្តិនេះជាអង្វែងទៅ, អាត្មា

អញ មុខជាមិនបានសោយរាជ្យទេ, បើដូច្នោះ មានតែអាគ្នាអញដណ្តើមយករាជសម្បត្តិទើបគួរ", លុះគិតដូច្នេះហើយ ក៏ទ្រង់ប្រទានគ្រឿងពស្ត្រាករណៈ មាសប្រាក់រត្នៈនឹងគ្រឿងអម្ពរពស្ត្រាទាំងឡាយជាច្រើនដល់ពួកសេវកាមាត្យរាជមន្ត្រីដើម្បីឲ្យគេចុះចូលនឹងទ្រង់ ប្រមូលនឹងដណ្តើមយករាជសម្បត្តិ ។ គ្រាដែលអស្សុកមិត្តឧបរាជកំពុងតែប្រជុំពួកសេនា, ដូនជាមានអាមាត្យម្នាក់ជាអ្នកកតញ្ញូ ចូលទៅរកព្រះបរមពោធិសត្វ ហើយក្រាបបង្គំទូលរឿងនោះតាមការណ៍ពិតថា ៖

អវិកាសិ តុំ ទេវ តេ ហិ យាចិតុមាគតោ
ឧដ្ឋេហិ ទេវ សីឃម្ហិ អហំ វក្ខាមិ ការណំ
អជ្ជមេវ ឥមំ រត្តិ កនិដ្ឋោ តំ ឃាដេស្សតិ
អប្បមាទេន រក្ខាហិ អត្តានញ្ច អជ្ជមេវាតិ ។

បពិតព្រះសម្មតិទេព, ព្រះអង្គធ្វេសប្រហែសហើយ; សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានអភ័យទោស, ទូលព្រះបង្គំជាខ្ញុំមកដើម្បីរំលឹកព្រះសតិព្រះអង្គ, សូមទ្រង់ក្រោកឡើងឆាប់ៗ, ទូលព្រះបង្គំជាខ្ញុំ នឹងក្រាបបង្គំទូលឲ្យសព្វគ្រប់តាមហេតុការណ៍; ក្នុងវេលារាត្រីថ្ងៃនេះ ព្រះអនុជព្រះអង្គប្រុងនឹងពិឃាតព្រះអង្គហើយ, សូមព្រះអង្គកុំប្រហែសឡើយ, ថ្ងៃនេះសូមទ្រង់ប្រយ័ត្នព្រះអង្គឲ្យមែនទែន! ។

ព្រះបរមពោធិសត្វទ្រង់ព្រះសវនាការស្តាប់ពាក្យអាមាត្យនោះហើយ ក៏ទ្រង់ត្រិះរិះក្នុងព្រះចិន្តាថា "បើសិនជាអាត្មាអញតតាំងច្បាំងគ្នា, មុខជាប្អូនអញព្រមទាំងពួកពលសកលយោធា នឹងវិនាសខូចខាតអស់ច្រើនពុំខាន, បើដូច្នោះ មានតែអាត្មាអញគេចជោះប្រាណរត់ចេញចាករាជដ្ឋានក្នុងវេលាពេលយប់នេះទើបគួរ" លុះទ្រង់ជញ្ជឹងរំពឹងគិតដូច្នេះស្រេច ទើបស្តេចទ្រង់ព្រះរាជទានរង្វាន់ ដោយសេចក្តីមេត្រីកប់អាន់ ចំពោះអាមាត្យនោះ ហើយទ្រង់បញ្ជូនឲ្យត្រឡប់ទៅវិញ, ទើបទ្រង់ស្តេចចូលទៅក្នុងសំណាក់ ព្រះនាងទេវីតែឯកអង្គ ទ្រង់ឱបព្រះរាជបុត្រាទាំងទ្វីថើបជញ្ជាបព្រះសិរសា ទ្រង់មានព្រះរាជឱង្ការត្រាស់ផ្តាំព្រះនាងទេវីថា: "ហៃប្អូនភ្ញាប្រិយ, ចូរស្រីនាងប្រុងប្រយ័ត្ន កុំប្រហែសកូនទាំងពីរណាស្ងួន! ចូរពុំងាទំថែរក្សាកូនកុំឲ្យអសុភមិត្តសម្លាប់បានឡើយ!" ហើយទ្រង់ត្រាស់ប្រាប់សព្វដំណើរសេចក្តីថា

(១) ម្នាលប្អូនស្រី, បងលាប្រឹមប្រិយទៅព្រៃហើយ, ព្រៃនោះ
មានសុទ្ធតែម្រឹគពាឡប្រេងឃ្នង, ជីវិតបងគួរឲ្យសង្ស័យណាស់
ប្រហែលជានឹងស្លាប់ក្នុងព្រៃធំនោះ តែម្នាក់ឯងទៅទេ
ក៏ពុំដឹង ៗ បងនឹងភៀសខ្លួនចេញទៅនៅក្នុងព្រៃហេមពាន្ត
ដែលមានតែពួកសត្វម្រឹគជាច្រើន, បងនឹងសាងសន្សំបុណ្យ

---

១ ពាក្យត្រង់នេះ ខាងបាលី លោកស្រង់យកពីវេស្សន្តរជាតក ត្រង់ហិមវន្តវណ្ណនា ។

បារមីគង់ព្រៃដែលដេរដាសដោយម្រឹគសាហាវ ជាទីនៅអាស្រ័យនៃសត្វមាសខ្លា, បូរពុំងាទាំងនៅសប្បាយរីករាយគង់តាមគុណបុះ ។

ព្រះនាងទេវីបានឮព្រះរាជឱង្ការដូច្នោះក៏ទ្រង់ត្រាស់ព្រះរាជសវនីយថា "បពិត្រព្រះបរមក្ដាស្វាមីម្ចាស់ថ្លៃប្អូនអើយ, ព្រះអង្គទ្រង់មានព្រះរាជឱង្ការថាម្ដេចដូច្នោះ?" ហើយ

ព្រះនាងកេសិនីទេវីដ៏ល្អល្អះសព្វអង្គឥន្ទ្រិយ មានព្រះរាជ-សវនីយក្រាបបង្គំទូលព្រះរាជស្វាមីថា ព្រះអង្គទ្រង់មានព្រះរាជឱង្ការដូច្នេះ ខ្ញុំម្ចាស់ពុំដែលឮទេ ! ព្រះរាជឱង្ការដែលព្រះអង្គទ្រង់ត្រាស់មកនេះ អាក្រក់ណាស់ពុំប្រសើរសោះ, បពិត្រព្រះរាជសម្ភារ ព្រះអង្គទ្រង់ស្ដេចនៅតែមួយព្រះអង្គឯងពុំសមគួរទេ, បពិត្រព្រះវរមក្សត្រ, កេសិនីខ្ញុំម្ចាស់ធ្លាប់គោរពប្រតិបត្តិ ពុំដែលលោះមួយវេលា; បើព្រះអង្គទ្រង់ស្ដេចទៅទីណា, ខ្ញុំម្ចាស់ស៊ូតែតាមទៅគង់ទីនោះផង, ខ្ញុំម្ចាស់ស៊ូតែស្លាប់ជាមួយព្រះអង្គ ពុំព្រមនៅរស់តែម្នាក់ឯងឲ្យចំបែងចិត្តព្រោះឥតស្វាមីទេ, តាមទៅស្លាប់ជាមួយនឹងព្រះអង្គ ប្រសើរជាងការរស់នៅដោយសេចក្ដីព្រាត់ប្រាសចាកព្រះអង្គ; បើខ្ញុំម្ចាស់ព្រាត់ប្រាសចាកព្រះអង្គហើយរស់

នៅ, ខ្ញុំម្ចាស់ទីងបង្គរភ្លើងឲ្យឆេះឡើងសន្ធោសន្ធៅ មានអណ្ដាតប្រសព្វគ្នាតែ ១ ភ្នក់ ហើយលោតចុះសម្រុកសម្លាប់ខ្លួនក្នុងភ្លើងនោះប្រសើរជាង; បពិត្រព្រះនរបតី, ដូចជាមេដំរីតែងប្រកៀកប្រកិតជាប់ស្អិត តាមដំរីឈ្មោលមានភ្លុកដើរតម្រុកទៅក្នុងព្រៃ ត្រេបនៅក្នុងពនាល័យ ជ្រោះប្រកញកភ្នំគិរី សព្វទីទាបទីទួលទំនួលខ្ពស់ ពុំឲ្យឃ្លាតឃ្លាសោះយ៉ាងណាមិញ; ខ្ញុំម្ចាស់ក៏ស៊ូតែពកូនសម្លាញ់ទាំងពីរ ទៅតាមព្រះភូមី ពុំឲ្យឃ្លាតដូច្នោះដែរ; ខ្ញុំម្ចាស់ ជាស្រីងាយចិញ្ចឹមណាស់, ពុំព្រមលាកលះព្រះអង្គឡើយ, បពិត្រព្រះម្ចាស់ថ្លៃប្អូនអើយ, ខ្ញុំម្ចាស់ពុំព្រមនៅជាសុខ ក្នុងព្រះនគរនេះទេ ។

លំដាប់នោះព្រះបាទក្រុងសុភមិត្ត ទ្រង់អង្វរករព្រះនាងកេសិនីជាអគ្គមហេសីថា ៖

ម្នាលប្អូនមាសពុំងា, នាងធ្លាប់តែលាយលាបស្រឡាបកាយាដោយក្របេះបួងបន្ទន់ មានសុគន្ធពិដោរ ក្រអូបក្រអែបជាប្រក្រតី, ឥឡូវនាងចង់តាមបងទៅនៅព្រៃ កេសិនីនាងបានអ៊ីលាប? នាងអើយ, ធម្មតាអ្នកនៅព្រៃ រមែងប្រឡាក់ដោយកក់ផង់ធូលីជាទីគួរខ្ពើមរអើមមមាមា, បើម្ល៉េះ

តើ ពុំងានាងចង់តាមទៅធ្វើអ្វី? ម្យ៉ាងទៀត កេសិនីនាងធ្លាប់ស្លៀកដណ្ដប់សុទ្ធសឹងតែសំពត់កាសិកព័ស្ដ ខោមកព័ស្ដ នឹងឧទុម្ពរព័ស្ដ មានពណ៌ល្អស្រស់ មានសាច់ទន់ល្មន់ល្វៃ, កាលបើនាងទៅនៅព្រៃ តើទេវីនាងស្លៀកកម្រងស្បូវក្រាំង មានសម្ផស្សរឹងគ្រាំង ដូចម្ដេចកើត? លក្ខណោ ម្នាលកេសិនីជាស្រីគ្រប់លក្ខណ៍, ការនៅក្នុងព្រៃមិនស្រួលទេ, តែងតែមានសេចក្ដីទុក្ខព្រួយជាប់ជាប្រក្រតី; បើដូច្នេះ ចូរប្រិមប្រិយនាងកុំទៅរងទុក្ខលំបាកឡើយ ។

ទើបនាងកេសិនីទេវី ដ៏ល្អល្អះសព្វអង្គឥន្ទ្រិយ ទ្រង់ឆ្លើយតបព្រះរាជឱង្ការព្រះរាជស្វាមីថា ខ្ញុំម្ចាស់ពុំចង់បានសេចក្ដីសុខដូច្នោះឡើយ; បើព្រាត់ប្រាសចាកព្រះអង្គហើយ ធ្វើម្ដេចឡើយ ខ្ញុំម្ចាស់នឹងរស់នៅបាន ។

កាលព្រះបាទសុកម្មិត្តបរមក្សត្រ ទ្រង់ឃាត់ដាច់អហង្ការក៏ព្រះអគ្គជាយាពុំព្រមសោះ, ទើបព្រះអង្គទ្រង់អនុញ្ញាតព្រមទាំងបំភ័យថា ម្នាលទេវី, ចូរប្អូនស្រីនាងប្រុងប្រៀបរៀបចំឲ្យឆាប់ៗចុះ, ការនៅក្នុងព្រៃនោះ រមែងមានសេចក្ដីលំបាកកម្រអត់ទ្រាំបានណាស់ មុខតែនឹងប្រទះពួកកណ្ដូបរបោមមូសស្រាំងស្រួយ ទឹងឃ្មុំជាច្រើន, សត្វទាំងនោះ

ទីងបៀតបៀនខាងក្នុងព្រៃនោះមិនលែង; មិនតែប៉ុណ្ណោះ ក្នុងព្រៃនោះ មានសត្វពស់ផ្សេងៗជាច្រើន គឺពស់វែកនាម ពស់វែកដំបូក ពស់វែកស្រែង ពស់វែកក្របី ពស់ព្រៃ ពស់ថ្លាន់ធំៗ នៅអាស្រ័យក្នុងស្ទឹង; ពស់ទាំងនោះ បើបានប្រទះមនុស្ស ឬ សត្វម្រឹគកាលណា រមែងរួបរឹតបរិភោគជាអាហារ; មានទាំងខ្លាឃ្មុំធំៗ សំបើមគួរខ្លាច, ខ្លានោះ បើបានឃើញមនុស្សហើយ, ទុកជាមនុស្សនោះរត់ឡើងដើមឈើ ក៏ពុំលែងដែរ តែងតែតាមទាំឲ្យខាងតែបាន; មានទាំងក្របីព្រៃស្នែងវែងៗ រមែងសម្លៀងសម្រួចសម្រាប់តែវ័ធ មានរូបរាងធំៗ ធាត់ៗ មុខគួរឲ្យខ្លាច រមែងចុះដេកត្រាំនៅក្នុងខ្សាច់ប្របស្ទឹងសោត្ថុម្ពក; បើសិនជានាងឃើញហ្វូងសត្វម្រឹគសាហាវយង់ឃ្នង់គឺទន្សោងគោព្រៃ ត្រេចឡើងចុះចម្រុះគ្នាក្នុងពនាល័យ តាមជ្រោះដងជ្រលងប្រកបចង្អៀត ហើយនាងឯងមានកូនផងទៀត ដូចជាមេគោបណ្តើរកូនខ្ចីយ៉ាងនេះតើ ស្រីនាងធ្វើដូចម្តេច? ម្នាលទេវី ក្នុងទីផ្លូវប្រកបចង្អៀតទាំងនោះ នាងឯងឃើញត្រឹមតែពួកស្វាដែលកាចៗប៉ុណ្ណោះ ក៏ប្រាកដជានឹងមានភ័យខ្លាំង, អម្បាលនៅក្នុងបុរីរាជវាំង ត្រាន់តែឮស័ព្ទមាត់ឆ្កែលូ ម្តេចនាងតក់ស្លុត

ញ័ររន្ធត់ទន់ខ្លួនដូចគេថ្ពច, បំណាន់បើបរត្របទៅកាន់ព្រៃ តើកេសិនីនាងធ្វើយ៉ាងណា? ហៃប្អូនម៉ាសពុំងា, ក្នុងព្រៃព្រឹក្សា តែដល់ថ្ងៃត្រង់ឡើងកាលណា ឮតែសូរស័ព្ទមាត់សត្វបក្សីទីទុយមៀមខ្វែងស្រាក់ដែលគួរខ្លាច មកប្រជុំគ្នាយំបន្ទាប គួរឲ្យព្រឺក្បាលព្រឺរោម, ចូរព្រលឹងនោមនាងកុំបង់តាមទៅឡើយ ៗ

កាលដែលព្រះបាទក្រុងសុកមិត្តបរមរាជា ទ្រង់ត្រាស់ដូច្នេះហើយ, ទើបព្រះនាងកេសិនីទេវី ដ៏ល្អល្អះសព្វឥន្ទ្រិយ ទ្រង់មានព្រះរាជសវនីយថា បពិត្រព្រះបរមពង្សអង្គក្សត្រា, ទុកជាព្រះអង្គត្រាស់ប្រាប់ថា ក្នុងព្រៃប្រកបដោយភ័យដ៏ពន្លឹកយ៉ាងណា ក៏ភ័យទាំងអស់នោះ ខ្ញុំម្ចាស់ស៊ូតែទទួលរ៉ាប់រងតាមកម្មពីព្រេង ត្រង់ដែលឲ្យខ្ញុំម្ចាស់នៅសម្រេងតែម្នាក់ឯង នោះនៅពុំបានទេ ស៊ូតែតាមទៅបំរើព្រះបាទា ពុំព្រមឲ្យឃ្លាតឃ្លាឡើយ; បើខ្ញុំម្ចាស់ដើរពុំរួច, ក៏ស៊ូតែលូនដោយទ្រូងកាត់ព្រៃញាតស្បាត ជៀតជែកញែកគុម្ពព្រៃសសិត បបុះរណ្ដាស ស្បូវ ស្មៅដំណេកទន្សាយ ខំកកាយវារលូនទៅពីខាងមុខព្រះអង្គ ពុំសុខចិត្តឲ្យស្ដេចលះបង់ ឲ្យនៅត្រមោចត្រមង់ជាស្រីមេម៉ាយទេ, ស៊ូតែទៅនៅរងទុក្ខ

ក្នុងព្រៃ ជាមួយនឹងព្រះស្វាមី ប្រសើរជាងនៅមេម៉ាយ ! ធម្មតាកុមារីទាំងឡាយ ទំរាំតែបានស្វាមីមួយ ៗ នោះដោយសេចក្ដីប្រព្រឹត្តិវត្តប្រតិបត្តិច្រើនប្រការណាស់ គឺ ដោយខ្លាចពោះធំប្រលើសឡើង ពុំបញ្ចេញរាងស្ដើតឆើតទ្រង់ ក៏រមែងរុំពោះរុំដោះ ដោយសំពត់ទឹងខ្ចិតរួតបង្រុំដោយឈើឈ្មោះគោហនុ(១) ហើយខំបំរើភ្លើងគឺខំយកចិត្តទុកដាក់នឹងត្រកូលរៀមច្បង ពោះបើនិយាយស្ដីនឹងអ្នកផង ក៏ដោយសេចក្ដីប្រុងប្រយ័ត្ន ក្រែងគេថាស្រីផ្ដេសផ្ដាស, ខ្លាចក្រែងសៅសម្បូរ ក៏ខំងូតទឹកព្រឹកព្រហាមខំផុសផុំឡើងឈាមឲ្យស្រស់ជាប្រក្រតី, ដល់វេលាបានស្វាមីហើយ ត្រឡប់ជាព្រាត់ប្រាសនិរាសចោលគ្នាជាស្រីមេម៉ាយទៅ ក្នុងទ្រូងសែនក្ដៅឆេះធ្លូលឈឺផ្សា ជាទុក្ខវេទនាណាស់ព្រះអង្គ បពិត្រព្រះបមពង្សអង្គនរបតី, សូមទ្រង់មេត្តាប្រោសដល់កេសិនី, ខ្ញុំម្ចាស់សូមតាមព្រះបក្រីទៅនៅក្នុងព្រៃ ជាមួយផង ៗ បពិត្រព្រះបមជន, ទុក្ខខ្ញុំម្ចាស់គ្រានេះពេញជាធ្ងន់ ព្រោះ

---

១ គោហនុស័ព្ទនេះ ប្រែថាឈើមានសណ្ឋានដូចថ្គាមគោ, ប៉ុន្តែដោយអ្នកកម្ពុជរដ្ឋ ពុំដែលប្រើ បានជាពុំដឹងហៅដោយភាសាខ្មែរថាដូចម្ដេច ។ ប្រហែលជាស្រី អ្នកមជ្ឈិមប្រទេសសម័យបុរាណ មានឈើនេះប្រើជាច្រើនគ្នា, បានជាក្នុងរឿងជាភាសាបាលី មាននិយាយពីកិច្ចវត្តរបស់ស្ត្រី ដែលដំសាច់ខ្លួនដោយឈើនេះជាប្រើនអន្លើ ដូចរឿងនាងបិញ្ចាជាដើម ។

បានយល់ពិតថា ធម្មតាស្រីមេម៉ាយជាទីមើលងាយនៃបុរស, សូម្បីស្រីនោះឥតសេចក្ដីប្រាថ្នាផេសផ្ដាសសោះ ក៏បុរសហ៊ានចាប់បង្ខំទាំងអំណាចឥតកោតក្រែង; ប៉ុន្តែបើគេដឹងថាស្រីប្ដីលែង, គេនឹងគ្រវែងចោល ពុំបរិភោគរបស់សំណល់នោះឡើយ ដោយខ្ពើមជាប់ចង្រៃ! បើយ៉ាងនេះ, ទូលខ្ញុំម្ចាស់ប្រាកដជាប្រេះឆាក្ដៅផ្សាដូចគេចាក់គូររីក ដោយគ្រឿងសស្ត្រា; បពិត្រព្រះកស្ដា, សូមទ្រង់មេត្តា ឲ្យខ្ញុំម្ចាស់តាមទៅបំរើព្រះបាទាព្រះអង្គផង ៗ បពិត្រព្រះបម-ភាព, ធម្មតាស្រីមេម៉ាយ ជាទីមើលងាយនៃជននានាពួកមនុស្សប្រុសព្រើលជាច្រើនគ្នា តែងផ្ដល់សេចក្ដីទុក្ខវេទនាធ្វើឲ្យកើតអំពល់កន្លល់ព្រួយជាច្រើនប្រការ គឺអ្នកខ្លះហ៊ានចាប់សក់កញ្ឆក់ទាញទៅ ឲ្យដួលដេកនៅលើផែនពសុធា, អ្នកខ្លះហ៊ានសំឡក់សំឡឹងបំនេត្រាពុំព្រមគេបៀសដោយឥតរង្កៀសសោះ; កាលបើដូច្នោះ កូនទ្រង់ខ្ញុំម្ចាស់នោះ ទីងឈឺឆៀបក្ដៅផ្សាឧបមាដូចជាគេចាក់គេគួរដោយគ្រឿងអាវុធ; បពិត្រព្រះចមមកុដ, ខ្ញុំម្ចាស់ស៊ូតែបំបុត្ររត់តាមព្រះអង្គទៅ ពុំព្រមនៅទេ ៗ

ម្យ៉ាងទៀត មនុស្សប្រុសទាំងឡាយតែងមើលងាយស្រីមេម៉ាយ ថាជាស្រីមានសម្បុរកាយសោះកក្រោះអស់រសជាតិអស់ដម្លៃ ចុះថ្លៃដល់កំណត់ ជាស្រីងាយនឹងបបត់ពត់ឲ្យងាកបែរទៅតាមប្រាថ្នារបស់ប្រុស, កាលបើដូច្នោះ ពួកប្រុសទាំងនោះនឹងហ៊ានធ្វើកិរិយាដន្ទេញដន្ទូរ ឲ្យកើតសេចក្ដីកើរដូចជាក្អែកនឹងមៀម; បើតែយ៉ាងនេះ ទូលខ្ញុំម្ចាស់នឹងកំព្រៀមឈើធៀបក្ដៅផ្សានឹងប្រេះឆា ដូចគេចាក់រុកពុះទម្លាយពុំខាន; បពិត្រព្រះនរបតី, ខ្ញុំម្ចាស់កេសិនី សុំតែតាមព្រះបក្រីទៅ ពុំព្រមនៅជាស្រីមេម៉ាយទេ ។

ម្យ៉ាងទៀត ធម្មតាស្រីមេម៉ាយ ទោះបីនៅកងក្រុមញាតិទាំងឡាយ ដែលជាត្រកូលទូលំទូលាយ រុងរឿងដោយគ្រឿងមាសនឹងប្រាក់ពស្ដាករណៈឥតមានខ្វះអ្វី ក៏កុំគប្បីសង្ឃឹមថា អញមុខជាលែងត្រូវពាក្យគេរិះគន់ហើយដូច្នេះឡើយ, មិនមែនដូច្នោះទេ, ទៀងតែត្រូវមាត់គេជាប្រាកដ; បើរួចពីពាក្យបងប្អូន, គង់ត្រូវពាក្យកូនរបស់គេឬត្រូវពាក្យនរណាមួយដែលទុកជាធ្លាប់ស្រឡាញ់ជិតដិតស្និទ្ធស្នាលយ៉ាងណាក៏ដោយ គេនឹងថាឲ្យដោយសេចក្ដីមើលងាយថា "ស្រីនេះមេម៉ាយឥតប្ដី គ្មានការងារអ្វីគ្រាន់បំពាំមខ្លួនទេ, មុខតែវានឹងនៅនាំឲ្យវល់អំពល់ទុក្ខដល់យើង អស់

មួយជីវិតរ៉ា ជាប្រាកដ"; កាលបើយ៉ាងនេះ ទ្រង់ខ្ញុំម្ចាស់នឹងកុកកួលរំជួលក្តៅផ្សា ប្រែះឆាបែកជាពីរបីចំណែកពុំលែងឡើយ; បពិត្រព្រះកស្ណាស្វាមីខ្ញុំអើយ, ទុក្ខប្អូនគ្រានេះពេញជាមហាធ្ងន់ផុតវិស័យនឹងថ្លឹង, ហេតុដូច្នេះ គេសិទខ្ញុំម្ចាស់សុំតែបូះពន្ទុះបោលកន្ទួង ស្ទួងតាមព្រះកស្ណាទៅពុំព្រមនៅទេ ។

ម្យ៉ាងទៀត ដូចជាស្ទឹងព្រែកខ្វែកទន្លេដែលជាមេទឹកជល-ធារ បើឥតទឹកហូរជាធម្មតា ក៏ឥតបានការអ្វីឡើយ លោកហៅថាស្ទឹងអាក្រាត; ពុំនោះសោតទេ, ដូចជាដែនរាជ្យត្រចំណុះសីមា ដែលឥតស្តេច ឥតអ្នកសម្រេចការ ក៏លោកហៅថាជាដែនអាក្រាតដែរ, យ៉ាងណាមិញ; ចំណែកខាងស្រីមេម៉ាយទុកជាមានបងប្អូនទាំងឡាយដប់ម្ភៃនាក់ ក៏ហាក់ដូចជាស្រីអាក្រាត ដូច្នោះដែរ; កាលបើនៅជាស្រីមេម៉ាយដូចជាអាក្រាតកាយនៅខ្លួនទទេដូច្នេះ ទ្រង់ខ្ញុំម្ចាស់នឹងប្រែះបែករហែកចេញពីគ្នាជាប្រាកដពុំលែង; បពិត្រព្រះគម្ពង់, ខ្ញុំម្ចាស់សុំតែសូះពន្ទុះតាមព្រះអង្គទៅ ពុំព្រមនៅទេ ។

ម្យ៉ាងទៀត ដូចជារថ រមែងមានទង់ជាគ្រឿងកំណត់ឲ្យគេស្គាល់ប្រាកដបាន, ឬដូចជាភ្លើង រមែងមានផ្សែងជា

គ្រឿងប្រាកដ, ឬដូចជាដែន រមែងមានស្តេចជាគ្រឿងប្រាកដ, ដូចម្តេចមិញ; ជាតិស្ត្រី ក៏រមែងមានស្វាមីជាគ្រឿងប្រាកដដូច្នោះដែរ; បើឥតស្វាមី, ពុំពេញជាស្ត្រីទេ; ជាតិនេះ ខ្ញុំម្ចាស់កើតមកជាមនុស្សនឹងគេ គួររាប់ថាជាស្ត្រីពេញទីបាន ព្រោះមានស្វាមីពេញមុខ; ឥឡូវបើព្រះអង្គប្រោះបង់ឲ្យនៅមេម៉ាយ, ខ្ញុំម្ចាស់សែនក្តៅក្រហាយក្នុងចិត្តឥតឧបមា, ទ្រូងខ្ញុំម្ចាស់រីងខ្លោចផ្សា ប្រាកដជាប្រេះឆាបែកធ្លាយពុំខាន; សូមព្រះអង្គទ្រង់ប្រោសប្រាណ អនុញ្ញាត ឲ្យគេសិទ្ធិខ្ញុំម្ចាស់តាមទៅផង ។ សេចក្តីពិតដែលបណ្ឌិតបានប្រកាសទុកមកថា ស្រីឯណា ទោះបីជាធីតារបស់ត្រកូលអ្នកមានកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ កាលបើស្វាមីមានសេចក្តីថោះថោយធ្លាក់ខ្លួនជាអ្នកកំសត់ទុគ៌ត ក៏ស៊ូតែលំអុត រងសេចក្តីកំសត់ជាមួយផង, កាលបើស្វាមីចំរើនសិរីឡើងថ្កើងជាអ្នកស្តុកស្តម្ភ ក៏ជាស្រីស្តុកស្តម្ភជាមួយផង; ទេព្តាទាំងឡាយ តែងសរសើរស្រីបែបនេះ ថាជាស្រីមានក្រឹត្យកិរិយាកម្រមាននរណាធ្វើដូច, ស្រីបែបនេះ អ្នកផងគួរយកជាគ្នា; ហេតុដូច្នេះ សូមព្រះភស្តាកុំទ្រង់ជិនណាយនឹងខ្ញុំម្ចាស់; ដើម្បីឲ្យខ្ញុំម្ចាស់បានឈ្មោះថាស្រីមានសំពត់ស្វៀក

ជាទិច្ចតទៅ គួរតែព្រះបមពៅទ្រង់អនុញ្ញាតឲ្យតាមទៅផង កុំឲ្យនៅទុក្ខវេទនាខ្លាំងពេក; កាលបើផែនដីពុំទាន់បែករហែកហាលេបខ្ញុំម្ចាស់ឲ្យស្លាប់ទៅដរាបណា សេចក្ដីខ្លោចផ្សាក្នុងទ្រូងខ្ញុំម្ចាស់ជាស្រីមេម៉ាយ ក៏រឹងរឹតតែក្លាយខ្លាំងឡើងពុំស្ងប់ទៅដរាបនោះ; កុំថាតែឲ្យខ្ញុំម្ចាស់នៅទទេដូច្នោះ សូម្បីមាននរណាមួយ អាចឲ្យផែនដីទាំងមូល ដែលមានព្រំប្រទល់ដល់មហាសមុទ្រ ផ្ទុកសុទ្ធតែគ្រឿងរតនវត្ថុផ្សេងៗមកខ្ញុំម្ចាស់ ឲ្យតែដាច់ចិត្តស្រឡះពីព្រះស្វាមី ក៏កេសិនីខ្ញុំម្ចាស់ពុំព្រមដែរ ។

ស្រីណាអេះ? កាលបើស្វាមីមានទុក្ខ ហើយបែរជាចង់បានសុខចំពោះខ្លួនម្នាក់ឯង! តើបេះដូងស្រីនោះដូចម្ដេចទៅបានជាចិត្តខ្មៅអាក្រក់ម្ល៉េះ? ខ្ញុំម្ចាស់ពុំមែនជាស្រីចិត្តអាក្រក់ដូច្នោះឡើយ កាលៈបើព្រះមហារាជ ជាអ្នកចំរើនក្នុងដែនរបស់ជន ទ្រង់ចេញចាកព្រះរាជបុរី ទៅគង់នៅក្នុងព្រៃ កេសិនីស៊ូតែតាមព្រះអង្គ ដែលធ្លាប់ទ្រង់ព្រះរាជទានសេចក្ដីសុខគ្រប់ប្រការ ពុំព្រមនៅជាស្រីមេម៉ាយអនាថា កំព្រាឥតស្វាមីទេ(១) ។

(មានត)

---

១ សេចក្ដីភិលាបរបស់នាងកេសិនី តាំងពីខាងដើមមកដល់ត្រឹមនេះ ចំណែកខាងបាលីខ្ញុំបានពិនិត្យឃើញថា លោកអ្នកតែងរឿងនេះ បានដកស្រង់មកពីវេស្សន្តរជាតក ត្រង់ទានកណ្ឌ។

# រឿងសៅរ៍សោយ

(សិសោរជាតក)

## ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ បឹង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្ត្រាស្លឹករឹត

(តមក)

---

ក្សិណនោះព្រះបាទ ។ សំសៅរ៍នរនាថ ឃើញហោរហើយអ-
ម្ចាស់មានដំរាស់ ត្រាស់ប្រាប់ដោយដំ- ណើរសព្វឥតបំ-
ផ្លើសក្លាត់ឡើយណា ។ "ហោរអើយ! គួរស្តែង យប់មិញនេះឯង
អញផ្ទំនិទ្រា យល់សប្តិហាក់ដូច កំពូលប្រាង្គណ៍ប្រា-
សាទអញនេះណា បាក់ធ្លាក់ទីទៃ ។ ចូរហោរទាំងឡាយ
គន់គូរទៀងទាយ ដោយក្បួនសាស្ត្រសៃយ ឲ្យដឹងដំណឹង
នេះតើម្តេចនែ រាល់ខ្លួនទីទៃ វៃៗរួសរ៉ា ។
ដោយអញយល់សប្តិ ហោរមើលឲ្យគ្រប់ យល់កាចឬជា
ល្អឬអាក្រក់ ឬដូចម្តេចម្តា តើជាយ៉ាងណា
ឲ្យដឹងសេចក្តី" ។ ក្សិណហោរស្តែងស្តាប់ បន្ទូលសាស័ព្ទ
ពីព្រះចក្រី ហោរបើកដំរា រាល់គ្នាឃ្នាតខ្ទី
គន់គូររាសី ប្រែក្រតីតាមក្បួន ។ ហោរាគូររាស
ដោយប្រាជ្ញាឈ្លាស ចំពោះរាល់ខ្លួន សឹងតែត្រូវគ្នា

ប្រកបបួបជួន តាមដោយទូវក្បួន ឥតខុសពីគ្នា ៗ
អស់ហោរទាំងឡាយ ក្រញូក្រាបថ្វាត់ថ្វាយ បង្គំវន្ទា
ទូលតាមសំនួន នៃក្បួនសាស្ត្រា "បពិត្រករុណា
មេត្តានេះមួង ៗ យើងខ្ញុំគ្រប់គ្នា មើលគ្រោះកាចជា
សព្វគ្រប់ហើយហោង ពុំបេរនឹងប្រោស អស់ទោសនេះមួង
ទុកជាខ្ញុំល្អង ព្រះបាទអម្ចាស់ ៗ បពិត្រពជា
យើងខ្ញុំគ្រប់គ្នា ឃើញអាក្រក់ណាស់ នឹងកើតវិបតេ
ត្រូវពិតត្រង់ម្ចាស់ កំណត់នៅខ្វះ តែ ៧ ថ្ងៃ ៗ
ព្រះសៅរ៍ទេវតា នឹងចេញយាត្រា ចាកសួគាល័យ
មករួមកាសី នឹងអម្ចាស់ថ្ងៃ កុំម្ចាស់សង្ស័យ
កង់ព្រះទ័យា ៗ នៅ ៧ ថ្ងៃ ព្រះសៅរ៍នោះនៃ
នឹងសោយពជា ឲ្យម្ចាស់ចេញចាក ពីនគរា
ព្រាត់ប្រាសជាយា មុខមន្ត្រីផង ៗ បើដូច្នេះណា
កុំព្រោះពជា ប្រហែសឡើយហោង សូមរៀបផ្កាភ្ញី
ជាតូការផង កុំឲ្យមានហង កើតទុក្ខអំពល់ ៗ
លុះដល់វេលា ដែលសៅរ៍ទេព នឹងចូលមកដល់
ព្រះអង្គបូជា ភ្ញីផ្កាឲ្យយល់ ជាការមង្គល
ទទួលព្រះសៅរ៍ ៗ អង្វរសូមទោស ឲ្យលោកសន្តោស

ឲ្យបានបិតនៅ សម្បូរស្រើប អង្វរលោកទៅ
សូមឲ្យព្រះសៅរ៍ ទទួលបូជា ។ ម្ចាស់ធ្វើបួង្ហោះ
ព្រះសៅរ៍នឹងលោះ ឲ្យសុខវិញណា សេពសោយសម្បត្តិ
កស្ត្ររដ្ឋសីមា នូវនាងជាយា អគ្គមហេសី ។
យើងខ្ញុំគ្រប់គ្នា ទូលព្រះរាជា ឲ្យជ្រាបសេចក្ដី
មេត្តាអត់ទោស ប្រាណប្រោសប្រណី យើងខ្ញុំនេះខ្ញី
ជាខ្ញុំបាទា" ។

## បទពំនោល

កាលនោះឯអគ្គព្រះបាទ សិរីសៅរ៍នរនាថ ស្ដេចស្ដាប់នូវពាក្យហោរា ។
ថាឲ្យសំពះប្នោះណា ស្ដេចក្រេវក្រោធា ពន្លឹកអធិកខ្លាំងក្រៃ ។
ហាក់ដូចអគ្គីវិស័យ ឆេះក្នុងហឫទ័យ រន្ធត់អស់តាំងអគ្គប្រាណ ។
ឬមួយនឹងប្រៀបទៅឋាន ដូចនាគហាវហាន ត្រូវនឹងដំបងដែកណា ។
ត្រង់ចុងកន្ទុយអាត្មា ក្រេវក្រោធមហិមា ឧបមាប៊ីដូចម្ដេចមិញ ។
រីស្ដេចទ្រង់ព្រះក្រោធវិញ ដូចនាគនោះមិញ ឈឺផ្សាក្នុងព្រះទ័យណាស់ៗ
ទើបស្ដេចមានព្រះតម្រាស់ ហោរអើយម្ដេចអះ ឲ្យអញសំពះចុះចាញ់ ។
ព្រះសៅរ៍ទេវបុត្តនោះអញ ពុំព្រមចុះចាញ់ ពុំព្រមសំពះឡើយណា ។
ព្រះសៅរ៍នោះជាទេវតា ឯអញនេះណា ក៏ជាទេវតាណាហ៎ ។
ម្ដេចឯងឲ្យអញនេះទៅ បូជាព្រះសៅរ៍ អញពុំព្រមតាមឡើយណា ។

អញមានទ្វីបេស្ដា តគអ្នកឯណា ឧបមាទឹងអញនេះបាន ។
ពលរេហ៍សេនាអាហាន ហ្វឹនសែនកោដិលាន សឹងជាសម្រាប់អញឯង ។
មានទាំងជាទ្វីជាវែង ធ្នូស្នាលំពែង អញឯងមិនខ្លាចសៅរ៍ឡើយ ។
កើតមកជាស្ដេចចក្រហើយ ពុំត្រូវកន្ដើយ ត្រូវច្បាំងពុំត្រូវសំពះ ។
តតាំងឲ្យដឹងតេជះ ទោះចាញ់ទោះឈ្នះ នោះទើបហៅប្រុសគ្រាន់បើ ។
សៅរ៍នោះតែមួយទេតើ ម្ដេចហ៊ានសើរើ មោះមកបំផ្លាញអញបាន" ។
ក្សិណនោះហោរាគ្រប់ប្រាណស្ដែងស្ដាប់ស្ដេចមាន មានះរឹងរូសហ្នះណា ។
ទើបហោរក្រេញក្រាបវន្ទា ទូលព្រះរាជា តាមដោយដំណើរព្រះសៅរ៍ ។
"បពិត្រព្រះបាទបមពៅ រីឯព្រះសៅរ៍ ពុំបានឲ្យឃើញឡើយណា ។
ទោះទាំងស្រមោលឆាយា រូបរាងអង្គា នោះជាកំបាំងសូន្យសោះ ។
សូមទ្រង់មេត្តាសង្គ្រោះ កុំក្រោធផ្ទុះ តបផ្ដោះព្រះសៅរ៍ឡើយណា ។
សូមស្ដេចរៀបអស់ភក្ដា រណ្ដាប់រណ្ដា បូជាព្រះសៅរ៍ទើបបាន ។
ព្រះអង្គទឹងសុខក្សេមក្សាន្ដបរិបូណ៌ធនធានសូមទានស្ដេចតាមយើងណា" ។
ក្សិណនោះព្រះបាទក្សត្រា ស្ដាប់ពាក្យហោរា ពណ៌នាសេចក្ដីសព្វការ ។
ស្ដេចរឹងជាក្រោធមាល្យាយ ដេញហោរខ្ចាត់ខ្ចាយ ហើយមានព្រះរាជបញ្ជា ។
ឲ្យមន្ត្រីខាងយុទ្ធនា អគ្គបញ្ញា ចូលគាល់ព្រះអង្គឆាប់ឆ្វី ។

លុះដល់សេនាបតី ចូលគាល់ចក្រី នរបតីទ្រង់ត្រាស់ប្រាប់ថា ។
" តាំងពីថ្ងៃនេះឯណា ទៅដល់ទិវា គ្រប់ជា ៧ ពុំឃ្លាត ។
ចូរលោកប្រើនប្រែងសង្វាត ឲ្យពលឧហាត យាមល្បាតក្នុងនគរ ។
ទ្វារទាំង ៤ ទិសនោះណា ចូរដាក់យោធា រក្សា ១ ទ្វារ ១ ពាន់ ។
ទាំងប្រាសាទ ៧ ជាន់ ត្រូវដាក់ ១ ពាន់ ១ ជាន់ ៗ ដូចគ្នា ។
បើឃើញព្រះសៅរទេព ចូរឲ្យសេនា នាំគ្នាចូលកាប់សំឡាប់ ។
ពុំនោះឲ្យចូលចោមចាប់ ចងជាប្រញាប់ នាំមកឲ្យយើងធាប់ខ្ជា " ។
ក្សណនោះសេនាបតី លុតលាចក្រី ឃ្លាតខ្លីចេញមកចាត់ការ ។
រៀបចំអស់ពលបរិវារ តាមព្រះឧង្ការ ដោយមុខដោយងាររួសរាន់ ។
១ ទ្វារសឹងជា ១ ពាន់ ប្រាសាទសោភ័ណ ១ ជាន់ ១ ពាន់ស្រេចណា ។
សឹងតែប្រដាប់ប្រដា កាំបិតធ្នូស្នា គ្រប់គ្នាដោយដៃទទៃ ។
ខ្លះកាន់ខែលខាន់ប្រពៃ ចិត្តចង់យកជ័យ រំពៃនេត្រាធ្វេងស្តាំ ។
ខ្លះកាន់លំពែងលលំ ប្រយ័ត្នប្រុងចាំ ចាំចាប់នូវសៅរទេវបុត្រ ។
ឥតខ្លាចឥតមានតក់ស្លុត ចិត្តចង់ប្រយុទ្ធ ចិត្តមុតមិនខ្លាចឡើយណា ។
ពួកពលសកលយោធា ប្រើនក្រែមហិមា រក្សាគ្រប់ទ្វារជុំជិត ។
សេនាសុទ្ធសឹងរឹងប្ញទ្ធិ របឹងប្រឹងប្រិត ពិនិត្យសព្វទ្រគ្រប់ប្រាណ ។
ខ្លាចក្រែងព្រះសៅរចូលបាន ប្រយ័ត្នមិនហានប្រហែសដល់តិចឡើយនៃៗ

ប្រយ័ត្នទាំងយប់ទាំងថ្ងៃ គ្រៀងគ្រប់ដោយដៃ រំពៃគយគន់ពុំធ្វេស ។
ឯព្រះសិរសៅរ៍ធិបេស ស្ដេចក៏ពុំធ្វេស ប្រហែសព្រះអង្គអាត្មា ។
ស្ដេចទ្រង់មកុដសុវណ្ណ ជាត្បូងសោភា សឹងពេជ្ររលេចយល់យង់ ។
មរកតមណីរ័តន៍បញ្ចង់ ហើយទើបស្ដេចទ្រង់ ព្រះពស្ត្រប្រពៃប៉ាន់ប៉ាក់ ។
បេសលួសខ្សែស្រាយធ្លាយធ្លាក់ បក្សីកពាក់ បទុមក្រពុំមាល័យ ។
ស្ដេចទ្រង់សង្វារ័តន៍ថ្ងៃ កងកណ្ឋាមាសម័យ ពិទូរពិទាយទឹករល ។
ព្រះហស្តស្ដេចទ្រង់ធ្នូសិល្ប កៅទ័ណ្ឌមាស ស្រិលព្រះខ័នទូរម្ហូលសក្ដិជ័យ ។
ឥតថុចបីកកុំបឡើយនៃ រុងរឿងពេកក្រៃ ឧបមេយ្យដូចសីហៈណា ។
សម្ដេចសិរសៅរ៍ពជា ប្រុងប្រៀបអាត្មា ប្រយោជន៍ប្រយ័ត្នការអង្គ ។
ស្រាប់ស្រេចស្ដែងស្ដេចចាំរង់ តតាំងទឹងអង្គ ព្រះសៅរ៍ទេវបុត្រជាម្ដង ។
លុះដល់ពត្រីកន្លង បាន ៧ ហោង ព្រះសៅរ៍ទេវបុត្រនោះណា ។
ចុះមកសន្និតលក្ខណា ធ្វើឲ្យក្សត្រា ពុំដឹងអាត្មាឡើយនៃ ។
ក្សិណនោះសិរសៅរ៍ដៀសជ័យ កើតក្ដៅព្រះទ័យ វិស័យដូចឆ្កួតលេលា ។
ស្ដេចទតឃើញពលយោធា ដែលចាំរក្សា នៅនាប្រាង្គណ៍ប្រាសាទថ្ងៃ ។
ក៏កើតឆ្កួតក្ដៅហ្ឫទ័យ ស្ដេចហូតខ័នជ័យ ជាលដេញអស់ពលសេនា ។
អស់ពលសកលយោធា កិតកីយតក្កមា រួតរត់ប្រពូនទីទៃ ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ១៩

### ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នករាំងវៃឆ្លាសបើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

លុះកន្លងមកយូរថ្ងៃ ប៊ូឆូឲ្យអេញ៉ីញ ឡៅពីស៊ីលៀង ទទួលមាន់ថងដែល ប៊ូឆូប្រើទៅស្តាប់ការរាជការខាងស្រុកអួនសៀវនោះត្រឡប់វិលមក យកសេចក្ដីជំរាបប៊ូឆូថា ឥឡូវកងស៊ុនបានចាញ់ដៃអ៊ួនសៀវទៅហើយ ។ ឡៅពីបានស្តាប់ក៏ភ័យស្លុតរន្ធត់ចិត្ត ទើបសួរមាន់ថងថា ដែលអ៊ួនសៀវឈ្នះកងស៊ុនបាននោះដោយហេតុអ្វី? ។ មាន់ថងឆ្លើយថា អ៊ួនសៀវលើកទ័ពទៅវាយកងស៊ុនបាន ១ លើកទ័ពមកតទល់គ្នាក៏ថ្មោះការចាញ់ដៃអ៊ួនសៀវជាច្រើនគ្រា កងស៊ុនបានក៏ឲ្យទៅសង់សែនប្រចាំគយកំពស់ ២០ ព្យាម ហើយដញ្ជូនស្រូវនឹងចំណីអាហារទៅទុកក្នុងស្រុកជាច្រើន

គេណ្ណាសេនាទាហានឡើងរក្សានាទីសែនបន្ទាយមាំមួន ឯស្រុកចំណុះកងស៊ិនបាន ទាំងប៉ុន្មាន ក៏បកសំបុត្រប្តឹងចូលទៅកងស៊ិនបាន ថា អ៊ួនសៀវលើកទ័ពមកវាយស្រុកតូចស្រុកធំបែកខ្ចាត់ខ្ចាយជាច្រើនតំបន់ សុំឲ្យលើកកងទ័ពទៅជួយ កងស៊ិនបានឆ្លើយតបទៅវិញថា សេនាទាហានគ្រប់ស្រុកប្រែចិត្តមិនគិតជួយច្បាំងទេ មិនដឹងកាលណានឹងបានលើកទៅជួយឡើយ នោះស្រុកចំណុះទាំងអស់ឮឃើញសំបុត្រឆ្លើយតបដូច្នោះ ទាំងអស់គ្នាក៏តូចចិត្ត គិតស្រុះគ្នាចូលទៅចំណុះចុះចូលខាងអ៊ួនសៀវទាំងអស់, កងស៊ិនបានដឹងដូច្នោះ ក៏ធ្វើសំបុត្រចូលមកក្រាបទូលព្រះចៅហៀនតេសុំកងទ័ពលើកទៅជួយ ទាហានអ៊ួនសៀវចាប់បំរើដែលកាន់សំបុត្រនោះបាន កងស៊ិនបានក៏ប្រើបំរើឲ្យនាំសំបុត្រទៅដល់តៀវអៀនទៀត ឲ្យលើកកងទ័ពទៅជួយ បើមកដល់កាលណាឲ្យអុជភ្លើងជាសំគាល់ កងស៊ិនបាននឹងលើកទាហានវាយខ្ទប់ពីក្នុងមក ទាហានអ៊ួនសៀវក៏ចាប់បំរើនាំសំបុត្រនោះបានទៀត ហើយអ៊ួនសៀវបំបែកទាហានឲ្យទៅពួនបង្កប់ជា ២ កង ទាហានកងកណ្តាលធ្វើជាធ្លាយកំពែងចូលទៅ អ៊ួនសៀវឲ្យអុជភ្លើងឆ្ងាយពីបន្ទាយប្រហែល ៣០ សិន (១២០០ម.), កងស៊ិនបានឃើញពន្លឺភ្លើងដូច្នោះក៏សំគាល់ថា តៀវអៀនលើកទ័ពមកជួយ ក៏បើកទ្វារស្រុកចំហហើយលើកទ័ពចេញទៅ, ទាហានអ៊ួនសៀវកណ្តាលក៏ធ្វើជាថយរត់ទៅ ហើយអុជផាវជាសញ្ញាឡើង កងទ័ពដែលពួនបង្កប់

ទាំងសងខាង  ក៏លើកស្រែចេញមកវាយខ្ទប់ទាំងសងខាង  កាប់សម្លាប់ទាហានកងស៊ុនចានស្លាប់ជាច្រើនណាស់, កងស៊ុនចានរត់ចាក់ទ័ពត្រឡប់ចូលស្រុកវិញបាន,  អ៊ួនសៀវឲ្យទាហានដឹកអុងម៉ុងចូលទៅទំលុះឡើងកណ្ដាលស្រុក  ហើយយកភ្លើងដុតអស់ផ្ទះសម្បែងក្នុងស្រុក,  កងស៊ុនចានឃើញទាល់ច្រកគេផ្លូវវេះរត់ពុំរួច  ក៏សម្លាប់ភរិយាបុត្ររបស់ខ្លួនស្លាប់អស់រលីង  ហើយអារកខ្លួនឯងស្លាប់ទៅទៀត,  អ៊ួនសៀវត្រានេះបានទាហានកងស៊ុនចានទុកជាច្រើនណាស់ ។

ឡៀវពីបានឮដូច្នោះ  ក៏មានសេចក្ដីអាណិតកងស៊ុនចានដោយកងស៊ុនចានមានឧបការគុណ  បានទូលស្នើសរសើរគុណបំណាច់ថ្វាយព្រះចៅហៀនតេ ។  ទ្រង់ប្រោសឲ្យឡៀវពីបានជាចៅហ្វាយស្រុកផេងង្ងួនគួន ហើយគិតដល់ជូឡុង  ដោយមិនដឹងជារស់ឬស្លាប់ ។  បួចក៏សួរម៉ាន់ថង់ថា  អ៊ួនសៀវបានស្រុកប៉ាក់ហៃហើយ  កិត្តិស័ព្ទឮគិតដូចម្ដេចខ្លះ? ។ ម៉ាន់ថង់ឆ្លើយថា  ខ្ញុំបាទឮដំណឹងថា  អ៊ួនសុតនៅស្រុកហ្វួយណាំតាំងខ្លួនជាស្ដេច  ប្រព្រឹត្តទុច្ចរិតកំហែងកំហោកកេកកាស្ត្រប្រជាទាំងពួងវែកខ្ចាត់ខ្ចាយទៅជាច្រើន  អ៊ួនសុតឲ្យបំរើទៅប្រាប់ដល់អ៊ួនសៀវជាបងថានឹងបញ្ជូនត្រាសម្រាប់រាជ្យទៅឲ្យអ៊ួនសៀវនោះ  អ៊ួនសៀវមិនទាន់ជឿបានតបថា  ឲ្យអ៊ួនសុតជាប្អូនបញ្ជូនត្រាទៅឲ្យមុន  ឥឡូវអ៊ួនសុតនាំគ្រប់គ្រឿងសារពើទ្រព្យសម្បត្តិចេញពីស្រុកហ្វួយណាំ  នឹងនាំត្រាសម្រាប់

រាជ្យ ទៅឲ្យអ៊ួនសៀវៈនៅឯស្រុកគីដីរ បើអ៊ួនសៀវនិងអ៊ួនសុតជួបជុំគ្នា ក៏នឹងមានកំឡាំងច្រើនឡើង សូម្បីនឹងទៅកំចាត់ចេញក៏កម្រក្រៃក្រ ហើយណាស់ ការណ៍នេះសូមឲ្យលោកវិះគិតកុំឲ្យមនុស្ស ២ នាក់នេះ ចូលជិតគ្នាបាន ៗ ចូចូបានស្ដាប់ក៏នៅស្ងៀម ៗ

ឡៀពីមកគិតតែក្នុងចិត្តថា " គ្រានេះបានការស្រួលហើយ ចាំវិះ គិតប្រែប្រួលឲ្យផុតពីកណ្ដាប់ដៃចូចូទៅជាមុន ដើម្បីនឹងគិតការតទៅ" គិតហើយ ក៏ក្រោកឡើងគំនាប់ចូចូហើយថា ឥឡូវអ៊ួនសុតនាំគ្រប់គ្រួ នឹងសារពើទ្រព្យរបស់ទៅរកអ៊ួនសៀវហើយ ឃើញថាអ៊ួនសុតគង់នឹង លើកជម្រងមកលើស្រុកឈើដីរ ខ្ញុំបាទនឹងសុំទាហានយកអាសាលើកទៅ វាយស្កាត់កណ្ដាលផ្លូវឃើញនឹងបានដោយងាយ ៗ ចូចូឮឡៀពីថាដូច្នោះ ក៏ត្រេកអរណាស់ហើយថា វេលានេះស្ទើរពេលហើយ ចាំព្រឹកស្អែកខ្ញុំ នឹងចូលទៅក្រាបបង្គំទូលព្រះចៅហៀនតេទ្រង់ជ្រាបជាមុន ៗ ឡៀពីក៏ លាចូចូចេញទៅផ្ទះវិញ ៗ លុះព្រឹកឡើង ចូចូនឹងឡៀពីក៏ចូលទៅក្រាប បង្គំគាល់ ចូចូយកសេចក្ដីក្រាបទូលស្នើព្រះចៅហៀនតេថា ឥឡូវអ៊ួនសុត នឹងលើកទ័ពទៅសន្ធប់គ្នាជាមួយនឹងអ៊ួនសៀវ បើឈ្មោះទាំង ២ នេះបូល ដល់គ្នានឹងគ្នាហើយ គង់នឹងគិតការជាធំមាំមួនណាស់ ទូលព្រះបង្គំជា ខ្ញុំសូមព្រះរាជទានឲ្យឡៀពីលើកទ័ពចំនួន ៩ ម៉ឺន ចេញទៅចាំស្កាត់ វាយកណ្ដាលផ្លូវដែលអ៊ួនសុត នឹងលើកចូលទៅត្រង់ស្រុកឈើដីរនោះ ៗ

ព្រះចៅហៀនតេក៏យល់ព្រម ៗ ហើយចូឆ្នូទីងឡៅតីក៏ក្រាបបង្គំលាចេញមក បាត់វែងរៀបសេនាទាហានប្រគល់ឲ្យឡៅតីចំនួន ៥ ម៉ឺន ៗ

ព្រះចៅហៀនតេ ឃើញចូឆ្នូទីងមន្ត្រីខ្ញុំរាជការឯទៀតលាចេញទៅអស់ហើយ នៅសល់តែឡៅតីក៏ទ្រង់ព្រះកន្សែងសោកាហើយត្រាស់នឹងឡៅតីថា ខ្ញុំមិនឃើញអ្នកឯណាក្រៅ នឹងនៅឈឺឆ្អាលសម្រាលទុក្ខរបស់ខ្ញុំ ឃើញតែមាម្នាក់នឹងពឹងពាក់ដម្រេះប្រាជ្ញាជួយគិតការតទៅឥឡូវមាចេញទ័ពទៅក្រៅហើយ កាលណាឡើយនឹងបានត្រឡប់វិលមកវិញ ៗ ឡៅតីក៏ក្រាបថ្វាយបង្គំលាទាំងក្រៀមក្រំពុំសប្បាយចិត្តនឹកអាណិតព្រះចៅហៀនតេពន់ប្រមាណ លុះបានទៅដល់ជួបនឹងចូឆ្នូក៏ប្រគល់ទាហានទាំង ៥ ម៉ឺនឲ្យឡៅតី ហើយឲ្យជូឡេងនឹងឡូដៀវ ២ នាក់អមឡៅតីទៅជាមួយ ៗ ឡៅតីក៏រកឫក្សពារជាមង្គល ដល់ពេលហើយក៏លះចូឆ្នូលើកទ័ពចេញទៅជាមួយនឹងគួនអ៊ូគៀវហ៊ុយ ចាកដែនក្រុងហ៊ូតោ ៗ ឯតាំងស៊ុនជីងថា ឡៅតីលើកកងទ័ពចេញទៅ ក៏ស្រូតទៅជួបនឹងឡៅតីធ្វើជួបជូនដំណើរកងទ័ព ហើយតាំងស៊ុនក៏ចូលទៅនិយាយខ្សឹបនឹងឡៅតីថា ការណ៍ដែលព្រះចៅហៀនតេទ្រង់មានព្រះតម្រាស់ឲ្យយើងរួមគិតគ្នា នោះកុំបីឲ្យអ្នកបំភ្លេចគេចមិនគិតឡើយ ៗ ឡៅតីតបថា “ការជាអាថ៌កំបាំងនោះខ្ញុំមិនភ្លេចទេ ខ្លួនអ្នកជាធំនៅកន្ទីនេះជាក្រោយខ្ញុំ ចូលខំត្រិះរិះហើយនឹងបិទបាំងកុំឲ្យខ្ចរខ្ចាយ បើខ្ញុំចេញ

ទៅបានគល់ការល្អវេលាណា ទឹងផ្ដើដំណឹងមកឲ្យអ្នកជ្រាប" ហើយក៏លាតាំងស៊ិនចេញទៅ ទំស្រែតលើកទ័ពតាំងថៃបុំតាំងយប់មិនឈរឈប់សោះ ។

គួនអ៊ូ, តៀវហ៊ុយនិយាយនឹងឡេវពីថា លោកលើកទ័ពគ្រប់គ្រមិនដែលស្រួតរូតប្រញាប់ដូចលើកទ័ពម្ដងនេះ ដែលលោកទំស្រួតប្រញាប់ដូច្នេះតើដោយហេតុអ្វី? ។ ឡេវពីតបវិញថា "ខុនយើងមកនៅកងកណ្ដាប់ដៃបូឆូបមាដូចជាសត្វបក្សាជាប់កងទ្រុង ពុំនោះសោតដូចជាមច្ឆាជាប់កងលប ឥឡូវគេបើកលែងឲ្យយើងរួចចេញពីទ្រុងនិងលបហើយ ក៏រមែងត្រេកអរសប្បាយ ត្រូវទំរូទានកាយ ស្រួតប្រញាប់ឲ្យដល់ទៅទីលំនៅ" ថាហើយក៏ឲ្យគួនអ៊ូ, តៀវហ៊ុយបង្ខំទាហានឲ្យស្រួតរូតដំណើរទៅ ។

ខណៈនោះ ធៀយ៉ុកនិងគុយកៃដែលបូឆូប្រើទៅនាំស្បៀងអាហារឯស្រុកក្រៅ លុះឮដំណឹងថា បូឆូប្រើឡេវពីជាមេទ័ពចេញទៅដូច្នោះ ក៏ភ័យណាស់ ទំស្រួតរូតត្រឡប់ចូលទៅក្រុងហ៊ូតោ ចូលទៅដំណឹងបូឆូថាហេតុម្ដេចបានជាលោកបើកឲ្យឡេវពីចេញទៅធ្វើមេទ័ពដូច្នោះ ។ បូឆូថាបានជាឲ្យឡេវពីចេញទៅនោះ ព្រោះឥឡូវនេះអ៊ួនសុតនឹងលើកកងទ័ពទៅសន្ធប់រួមដៃគ្នានឹងអ៊ួនសៀវ ដែលឲ្យឡេវពីលើកទ័ពទៅប្រយោជន៍បាំងស្កាត់ផ្លូវអ៊ួនសុត កុំឲ្យធ្វូងទៅបានត្រង់ស្រុកឈីជីវ ។ (មានត)

## នាលៈ និង ទមយន្តី

រឿងព្រេងប្រទេសឥណ្ឌា

# អ្នកស្រីស្រិន-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

*ប្រែពីភាសាបារាំងមកជាភាសាខ្មែរ*

(តមក)

---

ព្រះនាងមានបន្ទូលទៀតថា: "ឱព្រះករុណាដ៏មានរិទ្ធិ, បើសិនជាខ្ញុំម្ចាស់បានប្រព្រឹត្តអ្វីខុសនឹងសេចក្ដីស្នេហាព្រះអង្គ បើសិនជាស្ដេចភ្លេចនឹកដល់សេចក្ដីសប្បាយរបស់ព្រះរាជបុត្រាហើយ សូមតែទ្រង់គិតដល់ករណីយកិច្ចដែលជាធំរបស់ទ្រង់តែប៉ុណ្ណោះទៅចុះ, ពួករដ្ឋមន្ត្រីដែលគិតដល់វាសនាប្រទេសជាតិ គេនៅទីនេះទាំងអស់ ហើយគេមានសេចក្ដីក្ដារម្ភជាខ្លាំងណាស់ ដោយគេមិនដឹងជាហេតុអ្វី បានជាទ្រង់ប្រព្រឹត្តព្រះរាជចរិយាបែបនេះ, ចុះព្រះអង្គមិនឮសំឡេងរាស្ត្រស្រែកគឹកកងលាន់ឮក្រេវៗ ដូចជាខ្ញុំម្ចាស់ទេឬ? បណ្ដារាស្ត្រប្រជ្រៀតគ្នានៅក្លោងទ្វារព្រះបរមរាជវាំង ស្រែកឲ្យគេបើកទ្វារឲ្យ ដើម្បីនឹងមកបញ្ចេញនូវសេចក្ដីទោមនស្សរបស់គេនៅចំពោះព្រះភ័ក្ត្រព្រះអង្គ, ទាល់តែដល់ម៉្លោះឬទើបស្ដេចលះបង់ល្បែងបៀនេះចេញ?" ។ វេលានោះ ព្រះបាទនាលៈ មិនទតព្រះនាងទមយន្តីទេ ទ្រង់ព្រះតម្រិះតែបោះឡុកឡាក់ ។

ព្រះនាងទមយន្តីទ្រង់យល់ថាព្រះអង្គកែលចរិតហើយ ក៏ទ្រង់យាងត្រឡប់ចូលទៅក្នុងព្រះដំណាក់វិញដោយអៀនអន់ ហើយដាក់ព្រះភ័ក្ត្រផប់ ។

ព្រះនាងទ្រង់បីបមថ្នមព្រះរាជបុត្រទាំងពីរ ហើយមានព្រះបន្ទូលហៅ វាស្នេយ (Varshneya) ដែលជានាយអស្វបាល ហើយមានព្រះបន្ទូលថា: "វាស្នេយ ! ក្នុងចំណោមអាមាត្យស្តេចទាំងអស់ ឯងជាមនុស្សត្រង់ទីងមុំៗ ដឹងថា ឯងអាចទុកចិត្តនៃខ្ញុំបាន, ឯងដឹងស្រាប់ហើយ ថាព្រះករុណាជាម្ចាស់មានរោគកាច់ស្មាអាក្រក់មកគ្របសង្កត់, ទ្រង់ក្រសាលល្បែងភ្នាល់ជាមួយនឹងព្រះអង្គម្ចាស់បុស្ការ: ដែលជាព្រះអនុជព្រះអង្គហើយទ្រង់ចេះតែបរាជ័យ, យើងមិនដឹងជាស្តេចអស់ព្រះរាជទ្រព្យប៉ុន្មាននៅសល់ប៉ុន្មានទេ. ទ្រង់មានព្រះទ័យងប់នឹងល្បែងទាល់តែលែងឮពាក្យអង្គមន្ត្រីសំឡាញ់ទ្រង់អស់, ឯងមិនលែងឮគេនិយាយថា ទ្រង់មិនព្រមស្តាប់ពាក្យខ្ញុំផងទេ, ចូរឯងកុំស្មានថាខ្ញុំបន្ទោសស្តេច, វាស្នេយ ! ខ្ញុំគ្រាន់តែជាស្រីបំរើស្តេចប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំនៅតែព្រួយបារម្ភ ហើយខ្ញុំមិនចង់ឲ្យព្រះរាជបុត្រព្រះអង្គដឹងរឿងនេះឡើយ, ការវេទនាត្រូវធ្លាក់លើឪពុកនឹងម្តាយប៉ុណ្ណោះ, ចូរឯងមើលការខុសត្រូវថ្វាយទ្រង់ផងណា, វាស្នេយ ! ចូរឯងយកព្រះរាជរថណាយ៉ាងមាំ យកសេះណាយ៉ាងលឿន ហើយចូរឯងដឹកនាំព្រះរាជបុត្រា-បុត្រីខ្ញុំទៅឯប្រទេសវិទគ៌:, ដល់ហើយចូរឯងប្រគល់ព្រះអង្គម្ចាស់ទាំងពីរព្រះអង្គ ថ្វាយទៅព្រះបិតាខ្ញុំ រួចចូរឯង

ទៅនៅបំរើស្តេចណាដែលមិនងប់ងឹងល្បែងឡុកឡាក់ ឲ្យសុខសប្បាយទៅចុះ” ។

វាស្ន័យតែទៅរកសេះមកថ្វាយព្រះរាជរថ, ឯព្រះនាងក៏នាំព្រះរាជបុត្រទាំងពីរមកដាក់រទេះ ។ ដោយព្រះនាងទ្រង់ព្រះកន្សែងផ្អិតផ្អក់ខ្លាំងពេក ព្រះនាងអួលណែនព្រះឧរាករកទឹកមានព្រះឧត្តរផងពុំបាន ។ វាស្ន័យធ្វើតាមព្រះសវនីយ៍ បាននាំព្រះរាជបុត្រទាំងពីរទៅថ្វាយព្រះបាទភិមៈ ។ ថ្ងៃមួយ នាយសេះក៏បានដំណឹងថា ព្រះចៅក្រុងអយុធ្យាព្រះនាមព្រះបាទ រីតុបទិៈ (Rituparna) ទ្រង់សព្វព្រះរាជហឫទ័យត្រូវការរកនាយសារថីដ៏មានថ្វីដៃ វាស្ន័យក៏ចូលថ្វាយខ្លួនជានាយសារថីស្តេចនោះទៅ ។

* * *

វគ្គទី ១៩

ព្រះបាទនាលៈនៅតែជាប់ព្រះទ័យនឹងល្បែង លុះកន្លងអំណាចនៃអាទិទេពកាលី ហើយទ្រង់ស្គាល់តែពីចាញ់ជរាប ។ លុះដល់គ្រឿងមាស, ប្រាក់, ត្បូងមុក្តា, ខោអាវ, នឹងព្រះពស្ត្រទ្រង់ បានទៅព្រះអគ្គមហាសប៉ុស្ការៈអស់ហើយ ព្រះអង្គទ្រង់រង្វេងដល់ទៅហ៊ានលេងដាក់ប្រទេស ហើយទ្រង់ចាញ់ទៀត ។ ក្នុងខណៈនោះ ព្រះអគ្គមហាសប៉ុស្ការៈមានបន្ទូលទៅកាន់ទ្រង់ ទាំងព្រះសម្រួលផងថា “លួមស្ទះល្បែង

ប៉ុណ្ណឹងចុះ តើទ្រង់នៅមានរបស់អ្វីទៀតដាក់ជាបំផុត ទ្រង់នៅសល់តែព្រះនាងទមយន្តីទៀតទេ” ។ ព្រះបាទនាលៈលុះទ្រង់ព្រះសណ្ដាប់ព្រះអនុជមានបន្ទូលដូច្នោះហើយ ព្រះអង្គទ្រង់ភ្ញាក់ស្មារតីក្រញាងហើយ ស្រាប់តែទ្រង់វិតក្កមួយរំពេច ។ ព្រះអង្គក៏ទ្រង់ក្រោកឈរមួយរំពេច ដោយគ្មានព្រះឱង្ការតបទៅវិញសោះ ទ្រង់ដោះព្រះពស្ត្រគ្រវាត់ចោលនៅទីនោះ ហើយទ្រង់មានព្រះអង្គទទេរត់ចូលទៅរកព្រះនាងទមយន្តី ដែលគង់ចាំព្រះអង្គក្នុងបន្ទប់ ។

លុះព្រះនាងយល់ស្ដេចយាងចូលទៅដល់ ព្រះនាងក៏មានបន្ទូលដោយព្រះសូរសៀងស្រទន់ថា: “ស្ដេចយាងមកដល់ហើយ ! ឱព្រះអង្គជាទីស្រឡាញ់ខ្ញុំម្ចាស់ គ្រាន់តែបានឃើញព្រះភ័ក្ត្រទ្រង់ក៏កើតសេចក្ដីសប្បាយ, ក្នុងពេលដែលមានជោគជ័យ ខ្ញុំម្ចាស់ស្រឡាញ់ទ្រង់, នៅពេលដែលទ្រង់មានទុក្ខ ខ្ញុំម្ចាស់រិតតែស្រឡាញ់ទ្រង់ថែមទៀត” ។ ព្រះបាទនាលៈទ្រង់ព្រះកន្សែង, ព្រះនាងជូតទឹកព្រះនេត្រលួងលោមព្រះអង្គ ហើយមានព្រះបន្ទូលថា: “ដោយព្រះអង្គស្ដេចយាងមករកខ្ញុំម្ចាស់វិញ គ្មានសំលៀកបំពាក់នៅជាប់នឹងព្រះអង្គដូចជាទារកទើបនឹងសម្រាល ខ្ញុំម្ចាស់ត្រូវបីបាច់ថែរក្សាព្រះអង្គឲ្យដូចជាគេថែរក្សាកូនខ្ចី ខ្ញុំម្ចាស់នឹងជួយគាំពារសេចក្ដីខ្សោយរបស់ព្រះអង្គ, តពីថ្ងៃនេះទៅ ខ្ញុំម្ចាស់នៅសល់តែកំណាត់សំពត់គំរាំងនេះ ១ ទេ ដែលយើងត្រូវស្លៀកដណ្ដប់

ជាមួយគ្នា ដូចេះយើងរិតតែរួមគ្នាជិតទៅទៀត” ។ ព្រះបាទនាលៈ ទ្រង់រំដួលព្រះទ័យពេក ហើយស្រវាឱបព្រះនាងទមយន្តី ។ ទ្រង់យកសំពត់គក់ពង្វឹងមកដណ្ដប់ ហើយនាំគ្នាចេញចោលព្រះរាជរោងជ័យ ។ ទ្រង់យាងដើរកាត់ទីក្រុង ពួកបណ្ដាប្រស្ដ្រនាំគ្នាមើលលាន់ដោយបញ្ចេញសេចក្ដីមេត្តា ប៉ុន្តែគ្មានអ្នកណាម្នាក់ហ៊ានយំបួលជ្រែកដល់ទ្រង់សោះ ។ ទ្រង់ចេះតែយាងរហូតដល់ស្រុកស្រែ ហើយក៏ទ្រង់យាងតាមផ្លូវមួយ លុះដល់យប់ទ្រង់ប្រទះឃើញខ្ទមមួយតូច ក៏នាំព្រះនាងចូលឈប់សម្រាកផ្ទំផ្ដាល់ផែនដី ។

* * *

វគ្គទី ២០.

លុះព្រឹកឡើង ព្រះបាទនាលៈទ្រង់តើនមុនព្រះនាង ទ្រង់ទតឃើញព្រះនាងផ្ទំមានព្រះកក្រញញឹមស្រស់ ព្រះអង្គក៏ទ្រង់ព្រះកន្សែងយ៉ាងខ្លាំង ។ ដល់ព្រះនាងតើនឡើង ឃើញទឹកព្រះនេត្រព្រះភស្ដា ព្រះនាងក៏មានបន្ទូលសួរថា: “ហេតុអ្វីបានជាព្រះអង្គទ្រង់ព្រះកន្សែង បើខ្ញុំម្ចាស់សប្បាយចិត្តយ៉ាងនេះទៅហើយ ដោយគ្រាន់តែបាននៅជិតព្រះអង្គប៉ុណ្ណោះ” ។ ព្រះបាទនាលៈទ្រង់មានបន្ទូលតបថា: “ឱព្រះនាងដ៏វិសុទ្ធ ! ព្រះនាងគ្មានកំហុសអ្វីទេ បងបានបំផ្លាញប្រទេស គេមិនព្រមឲ្យយើងជ្រកកោននឹងគេផង បន្តិចទៅទៀតប្រហែលជាយើង

កើតវេទនាដោយឥតអាហារបរិភោគមិនដឹង ចូរប្អូនស្តាប់បងឲ្យជាក់ ដ្បិតបងជាធំលើប្អូន ហើយជាប្រយោជន៍ដល់ប្អូនទេបានជាបងនិយាយៈ ផ្លូវនេះជាផ្លូវទៅប្រទេសវិទេហៈ ចូរប្អូនដើរតាមផ្លូវនេះទៅ ឲ្យសុខសប្បាយចុះ" ។

ព្រះនាងឆ្លើយថាៈ "ទេ! ព្រះអង្គមិនឃើញខ្ញុំម្ចាស់ញ័ររន្ធត់ ដោយគ្រាន់តែគិតឃើញថា មានមនុស្សកំណាចអាចមកពង្រាត់ប្រាស់យើងទេឬ? គួរអ្វីឲ្យខ្ញុំម្ចាស់បោះបង់ព្រះអង្គចោលនៅពេលដែលព្រះអង្គកំពុងតែមានទុក្ខ! ខ្ញុំម្ចាស់ត្រូវជាអ្នកលួងលោមព្រះអង្គ នៅពេលណាដែលព្រះអង្គអស់កម្លាំង ដូចជាបណ្ឌិតតែងពោលជារឿយៗថាៈ ស្រីជាគ្រូដ៏វិសេសសម្រាប់អ្នកដែលមានទុក្ខធ្ងន់ៈ ខ្ញុំម្ចាស់មិនដឹងជានិយាយអ្វីទូលព្រះអង្គទៀតទេ" ។

ព្រះបាទនលៈ ក៏មានបន្ទូលតបថាៈ "ពិតមែនហើយ សម្រាប់ទុគ្គតបុរស គ្មានមិត្តកក្តិ គ្មានគ្រូពេទ្យណាអាចផ្ទឹមនឹងស្រីបានឡើយ! ចូរព្រះនាងកុំស្មានថាបងបោះបង់សេចក្តីស្នេហារបស់ប្អូនបាន" ។

ព្រះនាងឆ្លើយថាៈ "ម្តេចក៏ព្រះអង្គទ្រង់បន្ទូលបង្ហាញផ្លូវទៅប្រទេសវិទេហៈ ហើយទ្រង់មានព្រះបន្ទូលឲ្យខ្ញុំម្ចាស់ដើរតាមផ្លូវនេះទៅ ហើយថាសូមឲ្យខ្ញុំម្ចាស់បានសេចក្តីសុខ! ខ្ញុំម្ចាស់ដឹងថាព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់ហើយ ប៉ុន្តែទ្រង់ខ្លាចខ្ញុំម្ចាស់រងវេទនា ខ្ញុំម្ចាស់ចង់ទៅឯប្រទេសព្រះវរបិតាខ្ញុំម្ចាស់ដែរ ប៉ុន្តែលុះត្រាតែស្តេចនាំខ្ញុំម្ចាស់ទៅ យើងនឹងនៅជាសុខសាន្ត

ទាំងពីរនាក់ ព្រះវរបិតាខ្ញុំម្ចាស់នឹងទទួលព្រះអង្គដោយមេត្រីភាព ហើយព្រះអង្គនឹងគង់នៅជាធំនៅទីនោះផង ” ។

– “បងដឹងហើយ ថាព្រះវរបិតាអូននឹងឲ្យបងនៅដោយសុខស្រួល ហើយទុករាជសម្បត្តិទ្រង់ដូចជារាជសម្បត្តិបង ទុកព្រះបរមរាជវាំងទ្រង់ដូចជាព្រះបរមរាជវាំងបង ប៉ុន្តែនៅកន្លែងណាដែលកាលពីមុន បងបានបញ្ចេញមុខដោយពេញកិត្តិយស ទាំងដោយយកសេចក្ដីសប្បាយទៅផ្សាយផងនោះ បងមិនយកសេចក្ដីទុក្ខ នឹងសេចក្ដីខ្មាសទៅបង្ហាញផងទេ ” ។

– “បើដូច្នោះ ព្រះអង្គកុំបង្ហាញផ្លូវនេះខ្ញុំម្ចាស់ទៀត ចូរយើងនាំគ្នាដើរទាំងពីរនាក់ទៅ កុំត្អូញត្អែរអ្វីទៀតឲ្យសោះ ” ។

ទ្រង់ក៏យាងកាត់កលចូលព្រៃជាមួយព្រះនាងទមយន្តី ដោយអត់ព្រះស្ងោយ ឥតទឹកសោយ ទ្រង់ផ្ទុំដោយដីយកមេឃជាដំបូល ។ ចួនកាលព្រះបាទនាលៈទ្រង់ព្រះកន្សែង ប៉ុន្តែព្រះនាងទមយន្តីចេះតែញញឹមដកប។

* * *

(មានត)

## ដំណើរអស្ចារ្យនៃលោកកា៉ស្ញបឺយូយេ

លោកយូកុស៊ី រៀបរៀង

### លោកវ៉ាយ-ប៊ុក ក្រមការ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(ត-ចប់ តពីខ្សែលេខ ៥)

---

### គតិអ្នកនិពន្ធ

នៅប្រទេសជប៉ុន, តែងបានបុត្រដែលមាតាបិតា ដកហូតយកកេរ្តិ៍មត៌កអស់ ព្រោះកូននោះទៅរៀបវិវាហមង្គលការនឹងស្ត្រី ដែលមាតាបិតាមិនព្រមព្រៀងសោះ, គេនៅគោរពបុរាណនិយមប្រទេស, ការណ៍ដែលដកហូតនេះ មកពីបុត្រប្រព្រឹត្តតាមពួកបណ្ឌិតក្មេងក្មាយ ៗ នេះជាផលនៃបំណងធ្វើមិនត្រូវទៅតាមកាលៈទេសៈ ដើម្បីនឹងឡើងទៅកាន់ឋានៈឧត្ដមក្នុងជីវភាព ។

មានមនុស្សខ្លះគិតថា ប្រទេសតណ្ហាហើយនឹងស្ថានសួគ៌ គឺជាប្រទេសតែមួយ ហើយថា ពួកបណ្ឌិតនឹងសត្វខ្លារស់នៅក្នុងព្រៃ ៗ កាលណាបើមនុស្សល្ងង់មិនចេះគិតអានសៀវភៅ ដែលគេធ្លាប់និយមយកទៅឲ្យរៀនសូត្រនៅសាលាចិន, មនុស្សនោះតែងមានចិត្តចង់ធ្វើត្រាប់នូវសភាពបុរាណ ហើយទុកនូវវត្ថុអ្វីទំនើប ឬវត្ថុដែលកើតនៅប្រទេសជប៉ុនថាជាវត្ថុថោកទាប ដូចអ្នកចែវទូកមិនប្រសប់ឡើងទៅខាងលើស្ទឹង ចែវម្ដងទៅមាត់ច្រាំងខាងឆ្វេង ម្ដងទៅមាត់ច្រាំងខាងស្ដាំ ៗ ពិតមែនតែបាន

អប់រំជាមុន, មនុស្សបែបនេះបញ្ចេញឲ្យឃើញថាយកវត្ថុពិតថាមិនពិត, សុចរិតទៅជាទុច្ចរិត, ហើយបើបិតាជាអ្នកល្ងង់ខ្លៅផង បិតានោះតែងតែពោលចំពោះបុត្រនូវពាក្យបុរាណ ឬសុភាសិតនៃបណ្ឌិតផ្សេងៗ បន្ទំ ដើម្បីនឹងប្រព្រឹត្តទៅតាមទំនើងចិត្តខ្លួន ។ មនុស្សនេះតែងធ្វើតាមពួកពាលដែលប្រព្រឹត្តសុទ្ធតែលាមកអប្រិយ, មិនបានប្រព្រឹត្តតាមពួកបណ្ឌិតដែលបំពេញកិច្ចប្រកបដោយអភិជនភាពនឹងសុចរិត ។ គេអាចឃើញញយនូវបិតាមាតា ដែលមិនចូលចិត្តនឹងការសិក្សា ដោយយល់ថាការសិក្សានាំឲ្យកូនក្មេងកាចហើយទុច្ចរិត, តែមានបិតាមាតាខ្លះអាចពិនិត្យនូវការសិក្សា ដោយពិចារណានូវផលល្អ ឬអាក្រក់ជាអវសាន ។

ដូចគ្នានឹងមនុស្សដែលកាន់ប្រឡំ ចំពោះការស្មាននូវសុខភាពរបស់ខ្លួន ដោយហេតុថា មិត្តសំឡាញ់នៃមនុស្សនោះ បានជាសះស្បើយនូវរោគរបស់ខ្លួន ដោយគ្រូពេទ្យបានដាក់ឱសថ, ចំណែករោគខ្លួនឯងក៏ត្រូវប្រើឱសថបែបគ្នា ។ បើបានដំណឹងថា អ្នកជិតខាងងូតទឹកសុខស្រួលសប្បាយ អ្នកទាំងនោះក៏ទៅងូតទឹកដូចគ្នា ។ អ្នកទាំងនោះបរិភោគឱសថដោយស្មាន, មិនបានពិនិត្យឲ្យច្បាស់លាស់, មិនបានយល់ថាសមាសភាពនៃបុគ្គលនីមួយៗផ្សេងគ្នា ដូចជាទ្រង់ទ្រាយមុខខុសគ្នា ។ ការសិក្សាដដែលដូចជាឱសថដដែល, មិនអាចយកទៅអប់រំ ឬបរិភោគបានគ្រប់ៗគ្នាទេ ។

* * *

## ៥ — ដំណើរទៅកាន់សុញ្ញប្រទេស

**Pays de desolation)**

លោក ក៉ូស៊ូប៊ុយូយេ មិនទាន់បានរលាស់ចេញពីបាទជើងនូវធូលីដី ដែលជាប់ពី "បូរាណនិយមប្រទេស" ដោយហោះហើរលើអាកាស មានផ្លូវឆ្ងាយដាច់ស្រយាល ។ ហោះចម្ងាយប្រាំបីពាន់យោជន៍, លោកបានឃើញភូមិភាគមួយដ៏ធំទូលាយ ហើយដល់លោកចុះមកដល់ដី, ទើបមានគេប្រាប់ថា ភូមិភាគនេះ គេហៅថា សុញ្ញប្រទេស ។ លោកបានអញ្ជើញទៅពំនាក់អាស្រ័យ នៅគេហដ្ឋានលោក មូកុសេន៍យ: (mokuzenya), រឺជីកាម៉ាជិ (Chikamachi) ។ វត្ថុបឋមដែលប្លែកជាងគេគឺ មនុស្សទាំងអស់មានប្រហោងនៅកណ្ដាលដើមទ្រូង ជាហេតុឲ្យពួកមន្ត្រីធំៗ អាចយកមនុស្សទាំងនោះ ទៅប្រើជាយានជំនិះបាន ។ មនុស្សទាំងអស់នោះ មានប្រាជ្ញាចង់ចេញឬ? អ្នកទាំងនោះ ហៅទាសាពីរនាក់មក យកដងរែកស៊កទីប្រហោងដើមទ្រូង ហើយអ្នកទាំងអស់ក៏ឡើងទៅទីណាតាមប្រាថ្នា ។ ចំណែកខាងពិតាមាតាក៏បាននាំកូនទៅយកខ្យល់អាកាស ដោយទីងដងរែកដូចគ្រែខ្នងប្រអប់ ។ បើគេត្រូវការលោកគ្រូពេទ្យមកមើលរោគ មានមនុស្សដែលមានកម្លាំងមាំមួនទៅយកលោក មកដោយដោតដងរែកទៅក្នុងប្រហោងដើមទ្រូង ហើយក៏យកដងរែកនោះដាក់លើស្មានាំមក ។ បើតាមពិត ប្រហោងដើមទ្រូងនោះជាការងាយស្រួលក្នុងកិច្ចគ្រប់យ៉ាង, តែវត្ថុអ្វីដែលវិសេស គង់មានគុណវិបត្តិ ។

អ្នកប្រទេសនោះ មិនស្គាល់ច្បាប់នឹងសាសនាតាំងពីបុរាណសម័យមកយូរហើយ, វៀរលែងតែព្រះរាជប្រកាសមួយដែលហាមប្រជាជន មិនឲ្យមានសៀវភៅនឹងសិក្សាខាងទំនៀមទម្លាប់បុរាណ ។ មនុស្សម្នាក់ៗធ្វើការតាមទំនើងចិត្តហើយមិនមានអ្នកណាស្គាល់ការខុសត្រូវសោះឡើយ ។ ក្បាច់សិល្បៈនៃគេហដ្ឋាន, របៀបកាត់គ្រឿងសំលៀកបំពាក់ហើយនឹងអាកប្បកិរិយាប្រែប្រួលជានិរន្តរ៍ ហើយប្រជាជនសាកសួរតែរឿងរ៉ាវដែលឃើញនឹងភ្នែកប៉ុណ្ណោះ ។ ពួកនេះគ្មានគោរពគ្នាទៅវិញទៅមកទេ ។ ទាសាម្នាក់អាចពោលបានថា 'ម្ចាស់ខ្ញុំគឺជាមនុស្សដូចខ្ញុំដែរ ហើយដែលខ្ញុំបំរើគាត់ក៏ព្រោះគាត់ចិញ្ចឹមខ្ញុំ" ។ កូនប្រុសអាចពោលបានថា "ខ្ញុំមិនបានសុំបិតាមាតាមកកើតនឹងគាត់ទេ, 'គឺបុព្វហេតុមកពីគាត់ទាំងអស់ ព្រោះហេតុដូចនេះ បានជាគាត់មិនមានសិទ្ធិជេរស្តីបន្ទោសខ្ញុំទេ" ។ ភរិយាមិនស្តាប់បង្គាប់ស្វាមីទេ ហើយបុរសជំទង់ដែលមានកម្លាំងមាំមួនមិនមានចិត្តរួញរាក្រែងការឈ្លោះទាស់គ្នានឹងបងប្អូនរបស់ខ្លួន ។ អ្នកកម្លាំងជាងគេនឹងមានវ័យក្មេងជាងគេ អាចបានបរិភោគអាហារដ៏ប្រសើរនឹងស្លៀកពាក់ខោអាវល្អអស្ចារ្យ ។ សុញ្ញប្រទេស ជាប្រទេសវិសេសវិសាលជាបំផុតរបស់អ្នកទាំងនោះ ។ តែជនណាដែលចាស់ជរាត្រូវតែគេដេញចេញពីគេហដ្ឋាន ។ ជនចាស់ៗស្លៀកពាក់ខោអាវចាស់ៗហើយបរិភោគនូវអាហារជាមធ្យមតែងយល់ថា ប្រទេសនេះ ជាភូមិភាគក្នុងពិភព.

លោកមួយដែលមានសភាពលាមកជាងគេ, ហើយគួញផ្ទែរចំពោះការគ្មានកតញ្ញូនៃបុត្រ ។

លោក ក៉ស្ទូបិយូយេ បានស្តាប់ពួគេនិយាយនៅទីក្រុង នាគសគី (Nagasaki) អំពីប្រទេសមួយដែលស្វាមីកើតទុក្ខព្រោះប្រពន្ធមានគភ៌ ។ ដូចជាមានករណីយៈនៅស្រុកញ្ញប្រទេស, នាយកោជនាគារម្នាក់គួញផ្ទែរថាភរិយារបស់ខ្លួនមានគភ៌ជិតគ្រប់ខែហើយ ជិតប្រសូតិបុត្រ ។ ឯនាងជាភរិយាដើរទៅមកដូចសព្វមួយដងដក់ខ្សែ. ស្តីឲ្យស្វាមី ហើយបន្ទោសស្វាមីថា "មិនមែនជាអន្តប្រុស" ហើយមិនចេះទប់ទល់សោះ, នាងពោលថា "បើខ្ញុំមានគំនិតខ្វី ដូចជាស្វាមីខ្ញុំ ៗ មុខជារងបាបគ្រោះរហូតដល់មរណភាព" ។

ស្វាមីនោះបានឆ្លើយតបទៅប្រកាន់ប្រពន្ធវិញថា "វាមិនអាណិតអាសូរចំពោះការព្រួយលំបាកអញសោះ" ហើយកំញើញញ៉ុកមប្រពន្ធបន្ទំលែងលះពោល ។ នាងជាភរិយាក៏យល់ព្រមលែងលះ តែដល់ប្រសូតិបុត្ររួចក៏ត្រឡប់ជាសុខស្រួលនឹងគ្នាទៅវិញ ។

លោក ក៉ស្ទូបិយូយេ ក៏ចេញពាកប្រទេសនេះ ដោយចិត្តកោយ ហើយដិះក្រសារបោះទៅកាន់ទីឯទៀត ។

កតញ្ញូតាធិពន្ធ

គឺជាការខុសស្រឡះ ត្រង់ដែលមានមនុស្សខ្លះយល់ថា មនុស្សទាំងសត្វតិរច្ឆានមានសភាពផ្សេងគ្នា, បុគ្គលដែលមានគំនិតខ្វី ប្រព្រឹត្តតាម

សេចក្តីប្រាថ្នារបស់ខ្លួន ហើយគ្មេចសាសនាដែលប្រៀបមនុស្សដូចគ្នានឹងសត្វតិរច្ឆាន ។ គោគទ្រព្យធ្វើឲ្យមនុស្សពេញពលទន់ពន់ប្រមាណ ហើយមនុស្សនោះសប្បាយចិត្តពន់ពេក បើគ្មានអ្នកណាបានរកឃើញ នូវការប្រព្រឹត្តិលាមករបស់ខ្លួន, ដូចជាចចកដែលមិនមែនពុំស្គាល់អន្ទាក់ឬអន្ទប់ទេ, តែយល់ថាអញនឹងពិសោធន៍មើល ត្រង់ការអាស្រ័យចំណីនៅក្នុងអន្ទប់កុំឲ្យមានគ្រោះថ្នាក់ ។ ជីវភាពរបស់មនុស្សតិចតួចស្តួចស្តើងណាស់ ហើយមិនច្បាស់ប្រាកដ តែកម្មិកភាពចំពោះមនុស្សតែងបានផលអាក្រក់ល្អ ចួនកាលមកដល់ពេលក្រោយក៏មាន ។ បើតាមការសង្កេតក្តាម, ដូចជាមិនសមម្យេសោះចំពោះមនុស្សដែលមានជីវភាពប្រកបដោយជោគវាសនាល្អ ត្រឡប់ទៅជាគិតអនាគតទុកជាមុនទៅវិញ ។ តែមនុស្សដែលនៅសុញប្រទេសសប្បាយចិត្តតែនឹងពេលវេលាមិនទៀង, តែលែងគិតចំពោះអនាគតរបស់ខ្លួន ។ មិនមែនគ្រាន់តែពេគទេដែលនាំមកនូវទុក្ខគ្រប់យ៉ាងនឹងសេចក្តីលំបាកគ្រប់បែបគឺចិត្តបារម្ភទៀតក៏នាំមកនូវទុក្ខដែរ ។ គេត្រូវតែមានចិត្តស្មោះស្ម័គ្រមិនត្រឹមតែនាយចៅហ្វាយ, បិតាឬបងប្រុសរបស់ខ្លួនទេ ថែមរហូតទៅដល់មនុស្សគ្រប់ពិភពលោកទាំងមូល ។

*
* *

## ៦ .— ដំណើរទៅកាន់ប្រទេសយក្ខ

(Pays des Géants)

ពិតមែនតែលោក ក៏ស៊ូបយូយេ បានធ្វើដំណើរទៅកាន់ប្រទេសជាច្រើន លោកនៅតែមានថាមភាពមិនចេះអន់ថយសោះឡើយ, លោកនៅតែមានបំណងខ្លាំងក្លាចង់ធ្វើដំណើរតទៅទៀត ៗ លោកតាំងចិត្តថានឹងតម្រង់ទៅកាន់ស្ថានសួគ៌ នៅខាងបស្ចិមប្រទេស ដែលព្រះពុទ្ធគង់នៅ ៗ លោកបានចូលកាត់សមុទ្រខាងត្បូង ៗ ក្រសានោះហោះយ៉ាងលឿនបម្លាយប្រាំមួយរយពាន់យោជន៍ក្នុងមួយថ្ងៃ ហើយហោះក្នុងរយៈវេលាបីខែ ៗ រស្មីព្រះអាទិត្យអន់ថយចុះតាមលំដាប់, ហើយដល់ខែទីប្រាំទៅជួបប្រទេះនឹងងងឹតអន្ធការពេញលក្ខណៈ តែលោកជ្រាបថាលំដាប់តពីប្រទេសដែលគ្មានពន្លឺព្រះអាទិត្យព្រះចន្ទ មានប្រទេសមួយទៀតថ្មី ហើយលោកក៏បង្ខំក្រសាំនោះឲ្យហោះកាន់តែលឿនឡើង ៗ តើលោកនឹងក្រសាដែលចូលកាត់ប្រទេសងងឹតនោះ អស់រយៈវេលាប៉ុន្មានគ្មានអ្នកណាអាចដឹងបាន ដោយថ្ងៃនឹងយប់លាយលំគ្នានៅប្រទេសនោះ តែបន្តិចទៀតមានពន្លឺចេញពីទិសមួយប្លែក ហើយដល់ខែទីប្រាំបួន លោកអញ្ជើញទៅដល់ប្រទេសមួយទៀតប្លែកអស្ចារ្យ ៗ លោកក៏លោតចុះពីក្រសាអញ្ជើញទៅសម្រាកកម្លាំងនៅក្នុងព្រៃឫស្សី តែព្រៃឫស្សីនោះដល់ពិនិត្យឲ្យច្បាស់ទៅជាមានសភាពជាដើមស្រូវសាលីទៅវិញ ៗ វត្ថុទាំងអស់នៅក្នុងប្រទេសនោះ មានសភាពធំអស្ចារ្យ ដើមពិស្រង់លិស

(Pissenlis) មានទ្រង់ទ្រាយកំពស់ទឹងជនជាតិជប៉ុនដំណង ។ កាលណា លោកបានឃើញគេហដ្ឋានធំសម្បើមអស្ចារ្យ, ត្រពាំងទៅជាបឹងធំ គំនរសម្រាមដូចជាភ្នំហ្វូជី (Fuji), លោកគិតស្មានថា លោកវេទនារូបលោកឲ្យតូចទាប ដោយវិចារណញាណកំបាំងដែលគ្មានអ្នកណាអាចមើលយល់បាន ។ តែមិនជាអ្វីទេ ។ មានមនុស្សប្រុសស្រីធំសម្បើមអស្ចារ្យជាច្រើនពួកបានឃើញគាត់នៅទីនោះ ។ មានយក្សមួយបានចាប់លោកយកទៅហើយយកលោកទៅដាក់ក្នុងបាតដៃរ រួចសួរលោកថា អញ្ជើញមកពីណា? ហេតុម្តេចក៏បានជាទាបតូចតឿម្ល៉េះ? ។ លោកឆ្លើយតបទៅយក្សវិញថា លោកមកពីប្រទេសជប៉ុន ហើយបើទុកជាយក្សនោះប្រមាថលោកដោយលោកមានទ្រង់ទ្រាយទាបតូច, តែយក្សគោរពខ្លាចលោក ដោយលោកមានប្រាជ្ញាឈ្លាសវាងវៃ ។ ពួកយក្សក៏នាំគ្នាសើចខ្លាំង តែលោកឥតភ័យតក់ស្លុតទេ ។ មានយក្សមួយនាម "សាស្ត្រាចារ្យវិទ្យាសាស្ត្រសុខុម (le Professeur Science Profonde)" បានយកលោកមកកាន់ទឹងបាតដៃ ដូចជាទារកចាប់អំពិលអំពែកមួយហើយក៏នាំលោកយកទៅឯគេហដ្ឋានរបស់គេ បានជូនលោកពិសាទូរគ្រាប់បាយមួយធំប្រហែលនឹងផ្លែឪឡឹក ។ លោក ក៉ាសូប៊ឺយូយេ ឃើញខ្លួនលោកប៉ុនកូនចាប ។

ដំណឹងនេះ ក៏ផ្សាយខ្ទរទៅគ្រប់និគមជនបទថា មានសត្វមួយប្លែកមកដល់ទីនេះ, មានយក្សជាច្រើនមកមើល លោកក៉ាសូប៊ឺយូយេ,

លោកបានធ្វើឲ្យយក្ខទាំងនោះពេញចិត្ត ដោយលោកប៉ិនប្រសប់ខាង ពាក្យពក់ទាក់ពន់ពេក ។ លោកបានព្យាយាមធ្វើអាកប្បកិរិយាលោក ដូចជាអ្នកសប្បាយចិត្ត ហើយព្រមព្រៀង, បើលោកប្រកែកនឹងមាន គ្រោះថ្នាក់ធំតទៅអនាគត ។ លោកបានយល់ឃើញថា ការប្រូតស្រូវ សម្បូណ៌ពន់ពេក ហើយមានសព្វផ្ទាំឥតមានខានឡើយ តែលោកខំ ស្រាវជ្រាវចំពោះយក្ខទាំងនោះ នូវស្នាមគំនូសនៃការសិក្សាផ្សេងៗ អំពី ច្បាប់, សាសនា, សច្ចធម៌, មនុស្សជាតិនោះគ្មានសោះឡើយ ។ សូម្បីតែនាមឈ្មោះដោយបោរីភាព ព្រមទាំងមនុស្សធម៌, តុលាការ ក៏គ្មានដែរ ។ យក្ខប្រុសធ្វៀតឱកាសទៅក្នុងស្រែ យក្ខស្រីនៅគេហដ្ឋាន រវល់ដេរនឹងត្បាញរវៃ ។ ចួនកាលយក្ខទាំងនោះនាំគ្នាមកជួបជុំហើយ ជជែកគ្នា តែមិនបានទាស់ទែងគ្នាទេ ហើយរឿងរ៉ាវដែលពោលទាំង ប៉ុន្មានគ្មានខ្លឹមសារ ។ លោកក៏ស្ប៊ីយូយេ យល់ថាយក្ខទាំងនេះមាន ប្រាជ្ញាតិច ហើយពិតមែនតែលោកទាបតូចជាង លោកអាចបង្ហាញនូវ ផ្លូវពិតនៃជីវភាព ព្រមទាំងបំភ្លឺនូវច្បាប់ផ្សេងៗ ឲ្យយក្ខទាំងនោះស្តាប់ បាន ។ មានកាលមួយថ្ងៃ, ពួកយក្ខទាំងអស់នោះ បានមកសួរលោកៗ មានប្រសាសន៍ថា ពិតមែនតែលោកកើតនៅប្រទេសជប៉ុន, តែលោក បានធ្វើដំណើរទៅគ្រប់ប្រទេសក្នុងពិភពលោក ហើយលោកបានស្គាល់ ទំនៀមទម្លាប់ នឹងករណីយកិច្ចនៃយក្ខប្រុសទាំងនោះ ។ "អ្នកឯងនៅ

ប្រទេសដ៏ធំទូលាយមែនពិត, តែអ្នកឯងមិនស្គាល់នូវមនុស្សធម៌សោះឡើយ ។ នៅប្រទេសចិន បណ្ឌិតកុង-ហ្វុង ស៊ឺ, នឹង មិង-ស៊ឺ លោកបានបង្រៀននូវមនុស្សធម៌, នៅប្រទេសឥណ្ឌា ព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ព្រះអង្គបានបង្ហាញនូវមនុស្សគ្រប់គ្នា នូវលទ្ធិផ្លូវសួគ៌នឹងនរក, នៅប្រទេសជប៉ុន យើងបានឃើញនូវទេវតានឹងនាងទេពធីតាជាច្រើន ។ អ្នកណាដែលមិនស្គាល់មនុស្សធម៌ អ្នកនោះជាមនុស្សហីន-ជាតិពាលទុច្ចរិត" ។ លោកបានថ្លែងពិរោះជាងគេដូចពួកក៏គិន, បើទុកជាព្រះពុទ្ធរូបក៏គង់នៅស្ងៀមមិនបាន មុខជាឆ្លើយតបតមិនខាន; តែពួកយក្ខដែលស្តាប់ទាំងប៉ុន្មានគ្មានរំភើបអ្វីឡើយ ។ មានយក្ខម្នាក់នោះបានឲ្យពរសព្វសាធុការ នូវម្ចាស់គេហដ្ឋានដែលប៉ុនប្រសប់រកឃើញនូវវត្ថុអ្វីប្លែកជាងសុខ ដែលមានប្រាជ្ញាព្រមទាំងវត្ថុស៊ើបលេងកំសាន្តសប្បាយជាងបក្សាសេកទៅទៀត ។ ការដែលបកជ័យបំពោះសុន្ទរកថាដែលសូត្រនេះបញ្ជាក់ឲ្យឃើញថា អ្នកស្តាប់ទាំងប៉ុន្មានជាពួកល្ងង់ខ្លៅដោយពិត, ប្រៀបដូចជាយកម្ជុលទៅចាក់បាវ ដែលពេញទៅដោយកន្ទក់ ឬ ស្នូងកែដែកដែលក្តៅយកទៅដុតដី ។

ដល់អវសាន, លោកបានជំរាបទៅម្ចាស់គេហដ្ឋានថា "នៅប្រទេសគេឯទៀត ពិតមែនតែតូចជាងប្រទេសនេះ តែគង់គេបង្ហាញចំពោះប្រជាជននូវផ្លូវត្រង់មួយ (មគ្គសច្ច ឬ វិសុទ្ធិមគ្គ) សម្រាប់ឲ្យប្រតិបត្តិតាម,

គេបានពន្យល់អំពីគុណវិញ្ញូជន ឬ ជាគុណសម្បត្តិប្រាំយ៉ាងសំខាន់ៗ (យុត្តិធម៌, អប្បមាទធម៌, មត្តញ្ញុតា គឺការដឹងប្រមាណ និងពលភាព), គេមានច្បាប់ដែលឧបត្ថម្ភអកុពលភាព; នៅប្រទេសដែលល្អនៅខ្ពង់ដូចប្រទេសនេះ គុណសម្បត្តិខាងលើនេះគ្មាន, ដោយហេតុថា ខ្ញុំបានមកដល់ទីនេះ, ខ្ញុំពិសោធន៍បង់បង្ហាត់បង្រៀនពួកនេះឲ្យបេះដឹងខ្លះ, តែមិនបានសម្រេចដូចបំណង'' ។

អ្នកម្ចាស់គេហដ្ឋានញញឹម តែឥតមានឆ្លើយតបអ្វីសោះឡើយ ។ តែមានគេមកសួរបញ្ហាចំពោះអ្នកម្ចាស់គេហដ្ឋាន ។ ក៏ពោលថា -'អ្នកប្រហែលជាមានប្រាជ្ញាគ្រាន់បើ ហើយប្រហែលជាលោកអាចយល់នូវសេចក្ដីដែលខ្ញុំនឹងអធិប្បាយជំពបជូនដូចតទៅនេះ ។ មនុស្សធំឆ្ងាយពិបាកណាយល់នូវមនុស្សតូច ។ ពំបុកនឹងយល់មនុស្សធំ ។ សូម្បីតែក្មេងនៃប្រទេសនេះ ស្គាល់ដោយសុក្រិតនូវចិត្តគំនិតអធ្យាស្រ័យរបស់អ្នក ។ មនុស្សណាដែលជាអ្នកប្រាជ្ញថ្នាក់ទាបច្រើនយល់ថា អ្នកប្រាជ្ញថ្នាក់ខ្ពស់ល្ងង់ជាងខ្លួន ។ នៅមជ្ឈដ្ឋានចំពោះខ្លួនអ្នកៗ យល់ថាមជ្ឈដ្ឋាននោះមានប្រាជ្ញាជាងគេ ។ ហេតុម្ដេចក៏មនុស្សមានប្រាជ្ញាតិចតួចស្ដួចស្ដើងបែបនេះ យល់នូវប្រាជ្ញាដ៏ធំទូលាយនៃអគ្គបណ្ឌិត ដែលស្គាល់ពីដើមហូតដល់ចុងនោះកើត ។ អ្នកដែលមានចំណេះជាន់ទាបស្គាល់ចំពោះតែបុព្វហេតុនៃវត្ថុទាំងឡាយ ។ ព្រោះហេតុដូចនោះបានជា

ធម្មជាតិរបស់ឲ្យមានកើតបណ្ឌិតជាច្រើន ដើម្បីនឹងណែនាំអ្នកដែលត្រាច់ទៅកាន់ផ្លូវរង្វង់ឲ្យមកកាន់ផ្លូវត្រង់វិញ ប្រៀបដូចជាបិតាមាតាដែរបង្ហាត់បុត្រធីតា ។ ឧបាទ្ទៃបណ្ឌិតទាំងនោះមានប្រយោជន៍ចំពោះមនុស្សតូចតែម្យ៉ាង ឧបាទ្ធគឺជាប្រអប់មួយដែលគេប្រមូលមនុស្សតូច ៗ ដាក់ក្នុងប្រអប់នោះ ។ មនុស្សតូចទាំងនោះ ខំអំពាវនាវនូវឧបាទ្ធផ្សេង ៗ តែមិនអាចឃើញអ្វីពីក្រៅសោះឡើយ, តែមនុស្សធំអាចមើលឃើញស្គាល់ខាងក្នុងប្រអប់ ហើយពិចារណាពីខាងក្រៅថែមទៀត ។ អ្នកឯងគេឃុំឃាំងនៅក្នុងប្រអប់ពិភពលោក ហើយអ្នកឯងមិនអាចដឹងនូវបរលោកទៀត ។ អ្នកឯងអានសៀវភៅដូចជាក្មេងនិយាយមិនច្បាស់ ។ ព្រោះតែក្នុងពិភពលោក, មនុស្សសុទ្ធតែតូច ៗ ហើយប្រាជ្ញាក៏តិច, មានច្បាប់បទបញ្ញត្តិសុភាសិតដែលយើងមិនត្រូវការ ។ នៅក្នុងប្រទេសយើង, មនុស្សនៅទីនេះបានទទួលពីធម្មជាតិនូវប្រាជ្ញាដ៏ធំទូលាយ, មនុស្សទាំងនេះមិនដែលប្រព្រឹត្តនូវបាបអកុសលអ្វីឡើយ, តើយើងត្រូវការមនុស្សធម៌, យុត្តិធម៌, ពោរពេញទៅដោយច្បាប់សុភាសិត ហើយនឹងសាសនាមកធ្វើអី អ្នកឯងយល់ទេដែលយើងពណ៌នាជំពូកនេះ

ពាំស៊ូប៊ុយយេ !" ។ អ្នកម្ចាស់គេហដ្ឋានពោលជាអវសានតែប៉ុណ្ណោះ ហើយទូន្មានលោកពាំស៊ូប៊ុយយេ កុំឲ្យអួតអំពីប្រាជ្ញារបស់លោក ហើយចូរលោករស់នៅដោយសេចក្តីស្ងប់ស្ងៀមចុះ ។

លោក ក៏សូបីយូយេ ដល់បានឮសព្ទក៏ចានៃអ្នកម្ចាស់គេហដ្ឋានដូច នេះ, ក៏មានចិត្តអៀនអន់ពេកហើយគោតខ្លាចលោក "វិទ្យាសាស្ត្រសុខុម" ជាអនេក ៗ លោកយល់ថា ចំពោះយោបល់ល្ងង់ខ្លៅមនុស្សតូច, នឹង សេចក្តីយល់ឃើញដ៏ធំទូលាយនៃមនុស្សធំ គ្មានព្រំដែនទេ ៗ រួចលោក ក៏ឡើងជិះក្រសាវិលត្រឡប់មកកាន់ប្រទេសជប៉ុនវិញ ។

ចប់

## សត្រូវនឹងព្យាធិគេត្រូវកំចាត់ជាប្រញាប់

នរជនណាមិនបំផ្លាញសត្រូវប្តូជម្ងឺខ្លួន កុងពេលក៏ ទើបនឹងកើតឡើងទេ នរជននោះសូម្បីខ្លាំងពូកែយ៉ាងណាក៏ដោយ កាលសត្រូវនឹងព្យាធិនោះចំរើនឡើង ត្រូវក៏សម្លាប់ខ្លួនឯងវិញមិនខានឡើយ ៗ

បញ្ចូគន្ត្រ:

# ដំណើរតាមខ្យល់ក្នុងកក្តារៈ

## លោក ផេង-ជ្រើវ សាស្រ្តាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

### ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

សម័យនោះ រាលខ្នងភ្នំឡើងពណ៌ខៀវក្រមៅ ចុងភ្នំទាំងឡាយត្រឡប់មានពណ៌ពព្វក់, ឯណោះ ខាងនាយឆ្ងាយបន្តិច ពន្លឺព្រះអាទិត្យចាំងត្រូវសំពត់ដំរីដែលក្លាយពណ៌ទៅជាក្រហមដូចមាស ។

ធីតាទាំងពីរនៅឈប់ស្ងៀមមួយស្របក់ ។ ការណ៍ដែលបានប្រទះហេតុមិនបានជាគិតនេះ នាំប្រានារីបងប្អូនទៅក្នុងអន្ទង់ គឺសេចក្តីតក្កមិនចេះភ្លេច តែដែលនឹកជាងគេគឺនាងឡីឡា ។

កាលណានាងនឹកដល់រឿងព្រេង ដែលធ្លាប់បានស្តាប់ពីក្មេងអំពីព្រះអង្គម្ចាស់ដែលនាងជាប់ចិត្ត នាងមិននឹកអ្នកណាដទៃក្រៅពី អ៊ុស្លាអ៊ុលឡើយ ។ នាងស្រមៃឃើញមុខ ឃើញភ្នែកខៀវល្អក់ ឮសំដីតឹងបែបពីរោះនឹងស្រស់ ស្ថិតនៅក្នុងចិត្តជាធម្មតា ។ រូបអ៊ុស្លាអ៊ុលដែលបានពោលពាក្យដ៏ពីរោះទៅរកនាង ដែលបានសំដែងសេចក្តីគោរពដល់នាងជាស្ត្រីកំសត់រក្សាតែពាតែ នាងគ្មានភ្លេចទេ នាងរក្សាសេចក្តីរលឹកទុកនៅខាងក្នុងដួងព្រលឹងរបស់នាង ។

នាងហួចស្រែកហៅពពែ ហើយពីរនាក់បងប្អូនដើរប្រកិតគ្នា នាងឡើងកាន់ផ្លូវឆ្ពោះតម្រង់ទីសំណាក់អាស្រ័យ ។ មានអ្នកជិះសេះពីរនាក់

ពួននៅនឹងជើងភ្នំមួយ លបមើលនាង ។ មិនបានជាឃើញ ។ គេស្លៀកពាក់ជាអាពាប់ សំលៀកបំពាក់ព្រមទាំងគ្រឿងប្រដាប់សេះសឹងតែវត្តមានតម្លៃ អាចប្រាប់ឲ្យដឹងថាជាពួកអ្នកត្រកូលខ្ពង់ខ្ពស់ ។ លុះយល់ថានាងដើរកាន់តែជិតទីសំណាក់ហើយ ។ អាចស្តាប់ឮសូរសំដីអ្នកជំរំមកដល់ អ្នកជិះសេះក៏ព្រមគ្នាបរផ្លូវកាត់ប្រញាប់ដើម្បីឲ្យជួបនឹងនាង ។

ប្រហែលជានាងឮសូរជើងសេះផាយមកពីក្រោយ ឬមួយជាដោយសារពេលជិតយប់បានជានាងក្រមុំត្រូវប្រញាប់ ។ គ្រាន់តែអ្នកជិះសេះមកដល់ផ្លូវបំបែកនាងទាំងពីរនាក់ចូលក្នុងជំរំផុត គេក្រឡេកឃើញតែស្រមោលមួយភ្លែត ។ អ្នកជិះសេះមុនស្រែកជេរសេះ ហើយវាយសេះទាល់ហោះជើងពីរជើងបី បំណែកអ្នកម្នាក់ទៀតគិតតែពីសើច ។

អ្នកជិះសេះមុនស្រែកថា: "អញសែនក្តៅចិត្តអស់យ៉ាង" ។

គេតាំងវាយសេះបរបំផាយតាមផ្លូវកាត់ បត់ចូលដល់ជ្រុងទីសំណាក់របស់ជំរំនាងដែលទើបនឹងចូល ។

គេលោតចុះពីលើសេះភ្លាម ។ គូកនគេក៏ចុះដែរ ប៉ុន្តែក្នុងឱកាសដែលអ្នកទីមួយហូតកាំបិតស្នៀតចេញពីស្រោម ហើយបើកសំពត់ជំរំនឹងចូលតាម, អ្នកទី ២ ស្ទុះមកខ្សឹបនឹងត្រចៀកថាគ្មានជនណាមានសិទ្ធិត្រូវប្រើបទកំហែងក្នុងទីលំនៅអ្នកដទៃទេ ! ។

អ្នកទី ១ ឈោបែបទ្រឹង ហើយបញ្ចេញអាការមិនសប្បាយចិត្ត ក៏ត្រឡប់សិកកាំបិតទៅកន្សែងស្រោមស្បែកមានដាំស្ពូទតែត្បូងវិញ ។

ខណៈនោះ ជនទាំងពីរបានឮគួនពពៃយំទឹងសំណើចនៃនារីពីកន្ធំរមកហើយ គេហាក់ដូចជាធ្លាប់បានឮសំឡេងបែបហ្នឹងដែរ ។

បុរសទី ១ ទះទ្រូងហើយថា: អញសំណាងអាក្រក់ណាស់, សំណើចនេះនាំឲ្យអញចង់ឆ្កួត, ពីព្រឹកមិញ អញបានប្រទះសំណើចបែបហ្នឹងកាលដែលនាងទៅង្ងូតស្រាតនៅក្នុងជ្រោះ, របៀបសើចបែបហ្នឹង, អញស្គាល់ប្រាកដណាស់ ទៀងជានាងហ្នឹងហើយ រូបល្អណាស់ពុំ! ។

គេឈរដាក់មុខជ្រប់ចុះដូចតាំងសមាធិ ខាបស្រូបយករូបសម្បត្តិនាងឡូឡាដែលបានឃើញពីថ្ងៃមុន ។ លុះឈររំពឹងយូរទៅ គេនឹកឃើញសព្វ គឺស្មាសាច់ពេញហើយមាំ កម្ពូលស្អាត សុដន់ឡើងក្បមូលដូចបទុមបុប្ផាមិនទាន់រីក ទឹកជ្រោះយ៉ាងថ្លាហូរស្រោចពាសពេញខ្លួននាកណ្ដាលថ្ងៃ នាងមិនដឹងថាគេលបមើលហើយបញ្ចេញអាការៈដ៏ទន់ល្វន់ល្វាស ដូចកូនឈ្លូស ពត់ចុះពត់ឡើង ចំពោះធម្មជាតិ ។ ហើយគេនឹកដល់រូបនាងខាងក្នុង នៅព្រហ្មចារិយ៍ មិនដឹងជាស្អាតយ៉ាងណាម៉្លោះហើយសេចក្ដីត្រេកអរតែកើតឡើងជាទ្វេគុណ រួចគេប្ដេជ្ញាក្នុងចិត្តថានឹងយកនាងហ្នឹងឲ្យបាន ។ ហើយគេដកដង្ហើមធំ ។

ឃើញដូច្នោះ គួកនគេយកដៃទៅគោះឲ្យដឹងខ្លួន ហើយស្ដីឲ្យថាៈ កុច្ឆត! ហេតុអ្វីក៏ធ្វើឲ្យខាតពេលវេលាព្រោះតែតាមនាងនេះ? ចូរសំឡាញ់ថាឲ្យត្រង់មកមើល បើប្រសិនបាននាងហ្នឹងមក តើជាគាប់ប្រសើរយ៉ាងណា? នាងនេះជាស្ត្រីកំសត់ដើរទេសទេតើ! បើសំឡាញ់ចង់បាន មិនបេះខ្ទះទេ គគោកបែបហ្នឹង! ។

គេបើកក្បាលៈឡើង អ្វីក៏មិនថា ។

សំឡាញ់របស់គេមិនយល់ថា សេចក្ដីតម្រេកស្រកពនទន្ទ្រានក្នុងសន្ដានគេ ហើយថែមទាំងធ្វើគេឲ្យកើតមានកាមរាគក្នុងទឹកឈាម ដោយត្រវការបង់បាននាងព្រហ្មចារីយ៍ក្នុងកន្ទារៈនោះឡើយ ។

សំឡាញ់និយាយទៀតថាៈ ត្រវយើងទៅវិញ! ។

ជនទាំងពីរនាក់ដែលឡើងលើសេះដោយស្ងៀមស្ងាត់ៈ សៀមបេនអាប់ជាឡូសទីងមួហាម៉េតតេលុប ជាមិត្តភក្ដិអាក្រក់ នាំគ្នាវិលទៅទីក្រុងវិញ ក្នុងពេលព្រលប់យប់ស្ងាត់ ទាំងស្ដាយស្រណោះ ។

(មានត)

# ពិធីបុណ្យព្រហ្មទានក្នុងឆ្នាំ ១៩៥៤

## ពុទ្ធសាសនបណ្ឌិត្យ

---

កាលពីថ្ងៃទី ២១ ខែមីនាឆ្នាំ ១៩៥៤ នៅឯសាលាបាលីជាន់ខ្ពស់ មានពិធីបុណ្យប្រគេនព្រហ្មទាន ដល់និស្សិតសមណៈ ១២៦ អង្គ គឺនិស្សិតទើបប្រឡងចេញបានសញ្ញាបត្រសាលាបាលីជាន់ខ្ពស់ ចំនួន ៦៦ រូប និងនិស្សិតប្រឡងឡើងថ្នាក់នៅឆ្នាំទី ៤ ចំនួន ៦០ រូប ។

បុណ្យព្រហ្មទាននេះ កើតមានឡើងដោយសមាគមមិត្តសាលាបាលីជាអ្នកផ្ដើមធ្វើរៀងរាល់ឆ្នាំ ក្រោមអធិបតីភាពព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នៅឯសាលាបាលីជាន់ខ្ពស់ ៖ ពិធីបុណ្យលើកនេះជាលើកទី ៥ ។

ពិធីបុណ្យប្រគេនរង្វាន់ដ៏ប្រសើរ ចំពោះសមណសិស្សនេះ បានផ្ដើមឡើង តាំងពីយប់ថ្ងៃសៅរ៍ទី ២១ មីនា ពេលម៉ោង ៨ យប់ ដែលមានការជួបជុំពុទ្ធជិតគ្រហស្ថ ពុទ្ធបរិស័ទជាច្រើននាក់ ដើម្បីស្ដាប់ព្រះបរិត្តនិងធម្មទេសនា ។ នៅឯសាលាបាលីជាន់ខ្ពស់ មានការតាក់តែងលំអដោយទង់ជាតិទង់សាសនា រចនាដោយភ្លើងតាមក្លោងទ្វារ ជាពិធីបុណ្យមួយដ៏រុងរឿង ។

នៅថ្ងៃអាទិត្យទី ២២ ខែមីនា ម៉ោង ៣ រសៀល មានការជួបជុំពុទ្ធបរិស័ទ មានសម្ដេចព្រះសង្ឃនាយក ទីឯកឧត្តមបាន់ - ណាក ជាដើម បាននិមន្ត - អញ្ជើញទៅក្នុងពិធីបុណ្យនេះ ។ ដល់ម៉ោង ៥ រសៀល ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ស្ដេចយាងមកជាអធិបតី ហើយ លោកប៉ាយ - ប៊ុក អធិបតីសមាគមមិត្តសាលាបាលី បានថ្វាយសុន្ទរកថាក្នុងនាមនៃសមាគម ថ្វាយស្វាគមន៍ចំពោះព្រះប្រិយមហាវីរក្សត្រិយ៍ ទីងឥស្សរជនទាំងបព្វជិត ទាំងស៊ីវិល ដូចតទៅនេះ ។

ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្សជាអភិលក្ខិតសម័យនៃព្រះតេជព្រះគុណពល់ព្រះអគ្គ ទុកដូចជាបុប្ផាមួយដើមផ្កាយក្លិនក្រអូបឈ្ងុយឈ្ងប់ទាំងនាមសព្ទ ទីងគុណសព្ទល្បីទូទៅក្នុងព្រះរាជអាណាចក្រ ហើយទុកជាអនុស្សាវរីយ៍ដ៏អស្ចារ្យមួយក្នុងព្រះពុទ្ធសាសនា; ព្រះករុណា ជាសិស្សទាំងឡាយ ! ទេយ្យវត្ថុទាំងនេះ សម្រាប់បូជាចំពោះព្រះករុណាគ្រប់អគ្គ ដែលបានព្យាយាមសិក្សាគ្មានវេលាទំនេរអស់រយៈ ៤ ឆ្នាំ ទើបបានសម្រេចនូវចំណេះវិជ្ជាខាងផ្លូវព្រះពុទ្ធសាសនា ជាវិជ្ជាអាចផ្ដល់នូវសាធារណប្រយោជន៍ដល់ប្រជាជនរួមជាតិ ក្នុងកម្ពុជរដ្ឋ ។

សមាគមមិត្តសាលាបាលី មានសេចក្ដីសង្ឃឹមទុកជាមុនថា ព្រះតេជព្រះគុណគ្រប់អគ្គនេះហើយ នឹងបានជាគ្រូអាចារ្យនៃពួកឧបាសកឧបាសិកា ហើយជាអ្នករក្សាកេរ្ដិ៍ដំណែលនៃព្រះពុទ្ធសាសនា ឲ្យបាន

ឋិតថេរចិរកាលទៅអនាគត ។ សាលាបាលីជាន់ខ្ពស់ទុកដូចជាបិតាឬជាបុព្វាចារ្យ ដែលបានចិញ្ចឹមបីបាច់ថែរក្សាព្រះតេជព្រះគុណឲ្យបានចំរើនវ័យវឌ្ឍនាការ ឲ្យមានវិជ្ជាដែលជាហេតុរចនានូវដោតកេសនាព្រះតេជព្រះគុណឲ្យបានប្រកបដោយសុវត្ថិភាពគ្រប់យ៉ាង ។ សូមព្រះតេជព្រះគុណកុំភ្លេចសាលាបាលីជាន់ខ្ពស់នេះ បើព្រះតេជព្រះគុណគង់នៅជាភេទបព្វជិតក្តី សឹកទៅជាគ្រហស្ថក្តី ក៏ត្រូវជួយឧបត្ថម្ភសាលានេះព្រមទាំងសមាគមមិត្តសាលាបាលីដែលជាសរសៃរកន្ទោងសាលានេះ ឲ្យបានរស់រានមានជីវិតរឹងប៉ឹងដោយសាមគ្គីគ្នា ដើម្បីនឹងជួយឃុំគ្រងជាតិ សាសនា មហាក្សត្រិយ៍ ទាំងផ្លូវអាណាចក្រនឹងពុទ្ធចក្រ ឲ្យកុំស្ទាំងបែរមុខទៅរកវឌ្ឍនភាពនឹងសន្តិភាព ។ ដ្បិតប្រទេសកម្ពុជាដែលបានឯករាជ្យនេះ កំពុងត្រូវការវីរបុរសណាស់ ដើម្បីទូន្មានប្រៀនប្រដៅប្រជាជនខ្មែរ ឲ្យប្រតិបត្តិទាន - សីល - ភាវនាតាមពុទ្ធោវាទ, ព្រមទាំងឲ្យរៀនវិជ្ជាផ្លូវលោកផ្លូវធម៌នឹងធ្វើឲ្យរាប់អានភាសាអក្សរជាតិ ឲ្យបេះរក្សានូវអារ្យធម៌ខ្មែរ នូវកិត្តិយសខ្មែរ ឲ្យផ្សាយទៅពេញក្នុងសាកលលោក ។

ក្នុងអវសាននេះ សភាគមមិត្តសាលាបាលី សូមគុណព្រះរតនត្រ័យជួយឧបត្ថម្ភព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមទ្រង់គង់នៅជាសុខក្នុងសិរីរាជសម្បត្តិ ព្រមទាំងព្រះរាជវង្សានុវង្ស ! ។ សូមអសន្តិសុខវិនាសពីប្រទេសកម្ពុជាដោយឆាប់រហ័ស ! ហើយនឹងឲ្យឯកឧត្តម-អស់

លោកអ្នក បានបែកបដោយសិរីសួស្តីជយមង្គលគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

បន្ទាប់មក ព្រះតេជព្រះគុណព្រះពោធិវ័ង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ បានថ្លែងសុន្ទរកថាមួយបន្តមកទៀត រៀបរាប់អំពីការបែកស្ញើនេះថាជាកិច្ចអាចរាប់ចូលក្នុងការកុសល ដែលមានលទ្ធផលក្នុងបច្ចុប្បន្ននិងបរលោកបាន, និង សូមទទួលអំណរដ៏ក្រៃលែង ចំពោះសមាគមមិត្តសាលាបាលី ដែលធ្វើការកុសលដូច្នេះជាច្រើនឆ្នាំមកហើយដោយឥតរួញរា ហើយនិង សូមសំដែងនូវសេចក្តីគោរព ជាដំណាងបុគ្គលិកទាំងអស់ក្នុងសាលានេះ ចំពោះព្រះករុណា, សម្តេច, ឯកឧត្តមនិងអស់លោកទាំងឡាយ ដែលទ្រង់ស្តេចមកជាព្រះរាជាអធិបតីក្នុងឱកាសបុណ្យព្រហ្មទាននេះ ទុកដូចជានាំនូវសិរីសួស្តីដ៏ប្រសើរ មកព្រះរាជទានដល់សាលាបាលីជាន់ខ្ពស់, កិត្តិយសនេះនាំឲ្យសាលានេះមានដំណើរទៅកាន់សេចក្តីចំរើន ។

ហើយថ្លែងសេចក្តីក្រើនរំឭកប្រស្រ័យនិងសិស្សនៃសាលានេះ ដើម្បីអប់រំសតិបញ្ញារបស់សិស្សតទៅក្នុងអនាគតថា

ការរៀនសូត្រចំណេះវិជ្ជាគ្រប់ប្រភេទក្នុងលោកនេះ រមែងដឹកនាំមនុស្សជាតិនិងពិភពលោកឲ្យមានការប្រែត្រឡប់ពីអាក្រក់ទៅល្អ,ពីឋានៈថយថោកទៅកាន់ឋានៈដ៏ខ្ពង់ខ្ពស់, ពីការល្ងង់ខ្លៅទៅកាន់ការចេះដឹង ដូច

យើងបានឃើញនឹងភ្នែកស្រាប់ហើយ សេចក្តីចំរើនសេចក្តីចំរើនរុងរឿង ជាផលបានមកអំពីចំណេះវិជ្ជាៗ បានមកអំពីការរៀនសូត្ររបស់មនុស្ស ក្នុងលោក ៗ បណ្តាចំណេះវិជ្ជាទាំងនោះ, ការសិក្សាព្រះបរិយត្តិធម៌ នឹងវិជ្ជាដទៃ ៗ ក្នុងសាលាបាលីជាន់ខ្ពស់នេះ អាចរាប់បញ្ចូលទៅក្នុង ចំណេះវិជ្ជាផ្នែក ១ ក្នុងលោកបានដែរ ម៉្បីចំពោះប្រទេសកម្ពុជាយើងនេះ ជនជាតិខ្មែរយើងក្នុងអតីតកាល បានធ្លាប់និយមរាប់អានថាជាចំណេះ វិជ្ជាជាន់ខ្ពស់បំផុតរបស់ជាតិ ព្រោះគោលចារិកសំខាន់ ៗ នៃវប្បធម៌ ខ្មែរមានអក្សរសាស្ត្រជាដើម តាំងពីសម័យបុរាណរហូតមកដល់សម័យ បច្ចុប្បន្ននេះរមែងពឹងផ្អែកទៅលើព្រះពុទ្ធសាសនាស្ទើរតែទាំងអស់ ៗ

ហេតុនេះសុំឲ្យអស់លោកជានិស្សិតទាំងឡាយ ខំគិតពិចារណា ឲ្យវែងឆ្ងាយ ធ្វើចិត្តឲ្យធ្ងន់ឲ្យនឹងធឹង ហើយខំសិក្សាចំណេះវិជ្ជាទាំង ផ្លូវធម៌នឹងផ្លូវលោក ចំពោះតែវិជ្ជាណាដែលបព្វជិតអាចរៀនបាន ពុំ ទាស់គ្គងនឹងផ្លូវសាសនា ឲ្យបានចេះដឹងឲ្យបានសមល្មមជាទីពឹងបង្អែក នៃពុទ្ធសាសនិកជនតទៅ ដូចជាព្រះនាគសេនមហាថេរក្នុងសម័យអតីត កាល ដែលអាចតទល់នឹងចំណេះរបស់ព្រះបាទមិលិន្ទាធិរាជបាន ៗ

កាលបើព្រះតេជព្រះគុណព្រះពោធិវង្ស ចាងហ្វាងសាលាបាលី ជាន់ខ្ពស់ ថ្លែងសុន្ទរកថាដូចខាងលើនេះចប់ហើយ ព្រះករុណាជា

អម្ចាស់ជីវិតលើត្បូង ទ្រង់ថ្លែងព្រះរាជសាសន៍ទៅកាន់ព្រះសង្ឃ, នាម៉ឺនសព្វមុខមន្ត្រីនិងប្រជារាស្ត្រដូចតទៅនេះ ។

ខ្ញុំករុណាខ្ញុំសូមប្រគេន- ជូននូវសេចក្តីសោមនស្សរីករាយ សរ-សើរដល់ពួកសមណនិស្សិត ដែលមានភ័ព្វប្រឡងបានសញ្ញាប័ត្រ, និងដល់អស់លោកទាំងអស់គ្នា ដែលបានរៀបចំពិធីបុណ្យនេះ ជាកិច្ចទំនុកបំរុងការរៀនសូត្រក្នុងសាលាបាលីជាន់ខ្ពស់ ហើយបានបរិយាយសេចក្តីដែលបានត្រិះរិះគិតមក ។ ឱកាសនេះខ្ញុំករុណាខ្ញុំនឹងពណ៌នាជាសណ្តាប់ នៃព្រះសង្ឃនិងអស់លោក ដូចមានតទៅនេះ ៖

ដោយឃើញថា ប្រទេសនីមួយៗ បើចង់ឲ្យថ្កុំថ្កើងរុងរឿងលូតលាស់ទៅមុខទៀត លុះតែបណ្តុះបណ្តាលឲ្យឋានៈនៃចំណេះវិជ្ជារបស់ពលរដ្ឋប្រទេសនោះ បានលូតលាស់ខ្ពស់ឡើង ។

ចំណែកព្រះពុទ្ធសាសនាយើង ក៏មានស្ថានភាពដូច្នោះដែរ គឺថាសាសនាយើងដែលបានថ្កុំថ្កើងក៏ដោយសារវឌ្ឍនភាព ដែលមានក្នុងការអប់រម្យថេរានុត្ថេរ. ឲ្យបានចេះដឹងជ្រៅជ្រះកើនច្រើនអង្គឡើង ។

មួយយ៉ាងទៀត ក្នុងប្រទេសនីមួយៗ បើចំនួនជនដែលចេះដឹងកាន់តែរីកច្រើនឡើង រស្មីនៃអារ្យធម៌របស់ប្រទេសនោះក៏រីកឡើងដែរ ។

ចំណែកខាងពុទ្ធចក្រ បើវរសមណៈ មានចំនួនកាន់តែរីកទូលាយឡើង រស្មីនៃព្រះពុទ្ធសាសនាយើង ក៏កាន់តែរុងរឿងថ្លាចិញ្ចាចឡើងដែរ ។

ហេតុដូចម្ដេចក៏ថាចំណេះវិជ្ជានាំឲ្យកិត្តិយសដល់ប្រទេស, ដល់សង្គម, ដល់បុគ្គលឯកជន? ។

គេនិយាយថា វិជ្ជាអាចលើកឋានៈរបស់បុគ្គល ។ ហេតុអ្វីក៏ថាយ៉ាងដូច្នេះ? ។

ការនេះមិនមែនដោយសារតែបុគ្គលនោះមានសញ្ញាប័ត្រកាន់នៅដៃទេ. គឺមកពីអាចឲ្យសំគាល់បានថា បុគ្គលណាដែលស្វែងរកវិជ្ជានេះមកបាន បុគ្គលនោះឯងរមែងមានសមត្ថភាពធ្វើខ្លួនឲ្យរួចពីសេចក្ដីងងឹត គឺអវិជ្ជា ។ អវិជ្ជានេះហើយដែលជាហេតុដើម ជាមូលដ្ឋាននៃទុក្ខទោសរបស់មនុស្ស ព្រោះមនុស្សគ្មានវិជ្ជាពុំមានមូលដ្ឋាននៃការត្រិះរិះសំរាប់ពិចារណារកខុសត្រូវល្អអាក្រក់ទេ ។ អវិជ្ជានេះ ជាហេតុដើមនៃអំពើទុច្ចរិតទាបថោក ព្រោះមនុស្សគ្មានវិជ្ជា ពុំអាចមានឧត្ដមគតិខ្ពង់ខ្ពស់នៅក្នុងខ្លួន ។ អវិជ្ជានេះជាមូលដ្ឋាននៃអវិវឌ្ឍន៍ ពីព្រោះមនុស្សគ្មានវិជ្ជា ពុំមានសមត្ថភាពក្នុងវឌ្ឍនាការ ។

ចំណេះវិជ្ជារបស់ពលរដ្ឋ អាចនាំឲ្យពលរដ្ឋយល់ក្តីច្បាស់មែនទែនឡើង នូវសិទ្ធិនិងករណីយកិច្ចរបស់ខ្លួន, ឲ្យចេះបំរើប្រទេសជាតិឲ្យបានប្រសើរឡើង ធ្វើប្រទេសជាតិឲ្យមានអារ្យធម៌ បានចំរើនលឿនទៅមុខ ។

ចំណេះវិជ្ជា ចំណែកបព្វជិតប្រគេនលោកនូវមធ្យោបាយដែលនាំលោកឲ្យជ្រាបច្បាស់នូវខ្លឹមសារនៃព្រះពុទ្ធសាសនា នូវព្រះធម៌និងព្រះវិន័យ ។

ចំណេះវិជ្ជានេះប្រគេនសមត្ថភាពដល់ព្រះសង្ឃ ដែលអាចនឹងបំរើព្រះពុទ្ធសាសនា តំណាងព្រះពុទ្ធសាសនា និងផ្សាយព្រះពុទ្ធសាសនាឲ្យបានច្បាស់បរិសុទ្ធតាមគន្លងធម៌និងវិន័យ កុំឲ្យមានការកន្ត្រប្រឡំក្នុងការបកប្រែ ក្នុងការប្រតិបត្តិ និងកុំឲ្យមានការវង្វេងឆោតជឿតាមទំលាប់ខុស ៗ ដូច្នេះឃើញថា ចំណេះវិជ្ជាជាការចាំបាច់ ៗ

ប៉ុន្តែខ្ញុំករុណា ខ្ញុំចង់ពិតព្រះតេជគុណ, ចង់ជំពបអស់លោក-អ្នកថាចំណេះវិជ្ជាមានការទាក់ទងជាប់និងសុភនិច្ឆ័យ ព្រមទាំងលំអានរបស់វិន័យ និងសុចរិតយុត្តិធម៌ យើងនឹងញែកឲ្យបែកចេញពីគ្នាពុំបានឡើយ ៗ

ដូច្នេះឧបមាថា បុគ្គលមួយមានសញ្ញាប័ត្រនីតិបណ្ឌិត, ឬមហាបរិញ្ញាអក្សរសាស្ត្រឬបរិញ្ញាប័ត្រសាស្ត្រ តែបុគ្គលនោះចំណានតែខាងមើលងាយដល់អ្នកឯទៀត សូម្បីតែគេមានវ័យចាស់ជាងក្តីក៏ប្រមាទមើលងាយគេ ដោយគិតថាខ្លួនចេះជាង, ខ្លួនមិនត្រូវការស្តាប់សេចក្តីអ្វីឬរៀនការអ្វីអំពីមនុស្សណាទេ ៗ

ម្យ៉ាងទៀតឧបមាថា បុគ្គលនោះចេះស្គាល់តែសិទ្ធិរបស់ខ្លួន, ហើយពុំព្រមស្គាល់នូវករណីយកិច្ចខ្លួនផង ចេះស្គាល់ ចេះស្វែងរក ចេះមើលឃើញតែប្រយោជន៍របស់ខ្លួន របស់បក្សពួកខ្លួន, ពុំស្គាល់ប្រយោជន៍ប្រទេស ឬប្រយោជន៍សាធារណជនទេ, ចេះស្គាល់គុណទុក្ខធុរៈតែរបស់ខ្លួននិងពួកខ្លួន ហើយពុំព្រមស្គាល់នូវគុណបំណាច់ទុក្ខធុរៈរបស់

អ្នកឯទៀតទេ តើត្រូវទុកថាបុគ្គលនោះជាអ្នកចេះដឹងពេញលក្ខណៈជាអ្នកមានចំណេះវិជ្ជាបានឬទេ? ។

អ្នកពជការណាមួយ ដែលថាមានចំណេះ បើអ្នកនោះឯងជាមនុស្សទុច្ចរិត បើអ្នកនោះឯងជាអ្នកឥតសណ្ដាប់ធ្នាប់, ចំពោះវិន័យ ចេះតែមិនសុខចិត្តពីនេះពីនោះធ្វើបាបអ្នកតូច ហើយប្រមូលសព៌យទឹងអ្នកធំដោយខ្លួនមិនផ្សាយចែករំលែកសេចក្ដីយុត្តិធម៌ឲ្យទៅអ្នកតូច បើមិនចេះទទួលបញ្ជាដែលអ្នកធំគេដាក់ឲ្យប្រតិបត្តិដោយត្រឹមត្រូវតាមច្បាប់ ចេះទទួលមួយតែបញ្ជាណាដែលឲ្យប្រយោជន៍ដល់ខ្លួនផ្ទាល់ មន្ត្រីនោះឯងពុំឲ្យប្រយោជន៍ដល់ប្រទេសខ្លួនបានទេ ហើយសំគាល់ថាជាអ្នកមានវិជ្ជា ពុំបានឡើយ ។

ហេតុនេះហើយបានជាខ្ញុំករុណាខ្ញុំ បរិយាយអម្បាញ់មិញនេះថាចំណេះវិជ្ជាពុំអាចនឹងចែកញែកអំពីសុភនិច្ច័យ នឹងលំអានយុត្តិធម៌នឹងលំអានរបស់វិន័យបានទេ ។

សុភនិច្ច័យ ពាក្យបារាំងថា (le bansens) នោះគឺថាស្មាំពុំធ្វេងពុំមែនឈើយ ព្រោះមនុស្សខ្វះពិតមែនតែចេះច្រើន បុន្តែនៅធ្វេង រមែងគិត ឬធ្វើអ្វីទៅច្រើនផ្ទុយនឹងការត្រូវ ។

គិតធ្វេង ប្រព្រឹត្តធ្វេង អាចនាំឲ្យកើតគ្រោះថ្នាក់ ។

បើដូច្នេះ ព្រះតេជព្រះគុណនឹងអស់លោក អ្នកគង់ជាបគង់ឈ្វេងយល់បាននូវគំនិតរបស់ខ្ញុំករុណា ខ្ញុំ ។ ការរៀនសូត្ររមែងនាំខ្លួនយើងឲ្យចៀសរួចផុតពីអវិជ្ជា ។

អំពើច្វេនក្តី អំពើអយុត្តិធម៌ក្តី អំពើដែលមិនប្រកបដោយសណ្តាប់ធ្នាប់និងគន្លងច្បាប់គន្លងវិន័យក្តី ចូលក្នុងគន្លងអវិជ្ជា ។

មនុស្សមានចំណេះ ទុកជាចេះដឹងលើសលុបគ្មានកំបាំងអ្វីសោះ ហើយស្គាល់គ្មានខ្វះនូវអាថ៌កំបាំងនៃវិទ្យាសាស្ត្រ, បើមនុស្សនោះភ្លេចនូវលំអានតាមវិន័យ ករណីយកិច្ច-យុត្តិធម៌ សុកនិច្ច័យហើយ អាចក្លាយទៅជាគ្រឿងចក្រមួយ ដែលគ្រាន់តែវិលបង្កបង្កើតផលបាន ប៉ុន្តែពុំអាចចេះពិចារណាអំពីផលល្អ និងអាក្រក់ អន្តរាយនោះបានទេ ។

សេចក្តីដែលខ្ញុំករុណាខ្ញុំ ថ្លែងមកនេះ ប្រហែលជាមិនឃ្លៀងឃ្លាតអំពីដំបូន្មានព្រះសម្មាសម្ពុទ្ធបរមគ្រូដែលទ្រង់ត្រាស់ថា:

ពហុម្បិ ចេ សហិតំ ភាសមានោ នតក្ករោ ហោតិ នរោ បមត្តោ ជាដើម ដែលថា "ទុកជាចេះដឹងច្រើនយ៉ាងណា តែមិនប្រតិបត្តិឲ្យបានល្អតាមចំណេះ ជាការមិនមានផលប្រយោជន៍ប្រសើរប៉ុន្មានដែរ" ។

ដោយយើងស្រឡាញ់ប្រទេសយើងនេះហើយ ដោយយើងចង់ឲ្យប្រទេសយើងនេះ ស្គាល់នូវសេចក្តីរុងរឿងខ្ពង់ខ្ពស់នូវឯករាជ្យធំទូលាយ បានជាយើងខំស្វែងរកវិជ្ជានិងវឌ្ឍនធម៌ ។ ឯខាងព្រះពុទ្ធសាសនាវិញក៏ដូច្នោះដែរ ។

ប្រទេសយើងនៅថ្ងៃនេះ ដែលខ្ញុំករុណា ខ្ញុំ មានកិត្តិយសមកជាអធិបតីក្នុងពិធីចែករង្វាន់នេះ ទើបនឹងអន្ទិលចូលទៅកាន់ឯករាជ្យពេញទីក្រោយដែលបានទទួលផ្ទេរសមត្ថកម្មតុលាការ បញ្ហាការសឹកនឹងប៉ូលិសដែលជាកេតនភណ្ឌធំបង្អស់សម្រាប់ជាតិទាំង ៣ មក យើងទើបនឹងបានទទួលសមត្ថកម្មសេសសល់ឯទៀតទាំងឡាយ ព្រមទាំងអធិបតេយ្យភាពពេញទីខាងការទូតដែលយើងបានសម្រេចជាឯកច្ឆន្ទ ដោយរាជរដ្ឋាភិបាលមានខ្ញុំករុណា ខ្ញុំ ជាអធិបតីក្នុងការនេះ ទើបនឹងផ្តាច់ចោលជាអសារបង់នូវកិច្ចសញ្ញាពីមុនចំពោះរបៀបតាំងទូត គឺថាមិនចាំបាច់មានសេចក្តីយល់ព្រមពីប្រធានាធិបតី ប្រទេសបារាំងដូចមុនទេ ចាប់តាំងអំពីនេះតទៅយើងមានអំណាចបញ្ជូនទូតនៃប្រទេសយើងនឹងប្រទេសដទៃផ្ទាល់តែម្តង ៗ នៅសល់តែបញ្ហាហិរញ្ញវត្ថុ នឹងពាណិជ្ជកម្មក្រៅប្រទេសតែពីរមុខនេះទេដែលយើងនៅត្រូវយកទៅជជែកគ្នាទៀត នាក្រុងប៉ារីស ព្រោះនៅមានទាក់ទងគ្នានឹងប្រទេសវៀតណាម ហើយនឹងប្រទេសលាវផង ៗ

ប៉ុន្តែបើទុកណាជាយើងស្រាយបញ្ហាទាំងនេះបានស្រេច ក៏ប្អូនយើងកុំស្មានថាយើងអស់កិច្ចអ្វីដែលត្រូវបំពេញទៀតហើយនោះ កុំស្មានថាឯករាជ្យរបស់ប្រទេសយើងអាចរស់នៅ អាចមានរស្មីភ្លឺចិញ្ចែងដរាបដល់អវសានតទៅទៀតបាន ដោយយើង ពុំចាំបាច់ទ្រទ្រង់នោះ ៗ

បើអ្នកបំរើរាជការស៊ីសំណូក ហើយពុំរកប្រយោជន៍ឲ្យប្រទេសឲ្យសង្គមជាតិទេ បើសេនាទាហានមិនបំពេញបេសកកម្មរបស់ខ្លួនឲ្យពេញ

លក្ខណៈទេ ឬមិនគោរពវិន័យទាហានៈទេ បើសិស្សសាលានឹងនិស្សិត មិនព្រមបំពេញកិច្ចត្រឹមត្រូវស្មោះត្រង់ជាអ្នករៀនសូត្រទេ បើមនុស្សនៅតែគ្មានសណ្តាប់ធ្នាប់ នៅតែមានការប្រទូសរ៉ាយនឹងគ្នា បែកបាក់គ្នា នឹងបះបោរនៅតែកាន់អំពើទុច្ចរិត អយុត្តិធម៌មុសាវាទ នឹងបេសុញ្ញវាទ ឯករាជ្យដែលយើងទើបនឹងបានមកនេះ មុខជាដល់នូវមរណៈ ហើយប្រទេសយើងក៏ទៅជាមួយដែរ ។

ចំណែកខាងបព្វជិត ក៏មានករណីយត្រូវបំពេញដែរ ។

សេចក្តីខ្ពង់ខ្ពស់របស់ប្រទេសនឹងសេចក្តីរុងរឿងរបស់ព្រះពុទ្ធសាសនា ញុំាងឲ្យព្រះសង្ឃនៅតែភ្ជាប់នឹងករណីយកិច្ចរៀងរាល់អង្គ កុំឲ្យឃ្លាតពីវិន័យពុទ្ធបញ្ញត្តិ កុំឲ្យឃ្លាតពីចរិយាវត្តជាព្រះសង្ឃ ជាអ្នកបំភ្លឺផ្លូវ ជាគ្រូនៃយុត្តិធម៌ នៃវិចារណញ្ញាណនៃសុភនិច្ច័យ នៃរបៀបរៀបរយ នៃធម្មចរិយា នៃការទៀងត្រង់សុចរិតភាពនឹងខន្តី ដើម្បីឲ្យយើងទាំងអស់គ្នាជាគ្រហស្ថបានជ្រកនៅក្រោមម្លប់ដ៏ត្រជាក់នៃព្រះពុទ្ធសាសនាផង ឲ្យយើងបានស្រាកស្រាន្តពីសេចក្តីលំបាកក្នុងចិត្តគំនិតនឹងកាយ ហើយឲ្យយើងមានសេចក្តីសង្ឃឹមលើអនាគតដើម្បីមានសទ្ធាជ្រះថ្លាជួនលុមក្នុងកិច្ចដ៏លំបាក ដែលត្រូវបំពេញឲ្យប្រទេសជាតិមានជីវិតឋិតថេរចិរកាលតទៅមុខ ។

ជាតិយើង ក្នុងជីវភាពខ្លួននេះ និយមតែនូវវត្ថុពីរយ៉ាងគឺៈ ឯករាជ្យប្រទេសនេះ ១, សេចក្តីរុងរឿងព្រះពុទ្ធសាសនានេះ ២, ដែលយើងប្រាថ្នាចង់ឲ្យបាននៅគង់វង់ជានិច្ចកាល ។

ឯករាជ្យយើង នឹងបានចំរើនល្អលាស់ហើយនឹងបាននៅគង់វង់តទៅ បើពលរដ្ឋ ទោះបីមានរបរអាជីវៈដូចម្ដេចក៏ដោយ ចេះប្រកាន់ដោយខ្ជាប់ខ្ជួនថានឹងធ្វើការរបរខ្លួននោះ មិនត្រឹមតែដោយកម្លាំងកាយនឹងសតិបញ្ញាប៉ុណ្ណោះទេ គឺថែមទាំងត្រូវយកទៅបូជាក្នុងការនេះនូវសេចក្ដីស្នេហាការនឹងជាតិ សទ្ធាចំពោះករណីយកិច្ចខ្លួន ប្រតិបត្តិវិន័យចំពោះច្បាប់ សុចរិតយុត្តិធម៌ចំពោះសង្គមនឹងបុគ្គល ។

ព្រះពុទ្ធសាសនាយើង នឹងរុងរឿងក្ដីបំពែងបាន លុះណាតែព្រះសង្ឃបន្ថែមលើសេចក្ដីចំរើនដ៏អនេក ដែលលោកចេះធ្វើឲ្យបានមក ហើយក្នុងផ្នែកការសិក្សានោះ គឺបន្ថែមនូវសេចក្ដីចំរើន ដែលលោកប្រាថ្នាឲ្យបានសម្រេចក្នុងផ្នែកប្រតិបត្តិវិន័យ ដោយហ្មត់ចត់បរិសុទ្ធគ្មានខ្ចោះ ព្រមទាំងក្នុងផ្នែកសង្គមកិច្ចដែលជំបូន្មានព្រះពុទ្ធអង្គ អាចញ៉ាំងឲ្យលោកទាំងនោះ ជូនជាប្រយោជន៍ដល់ប្រទេសជាតិយ៉ាងស្ដុកស្ដម្ភទៅបាន ដោយព្រះសង្ឃនោះហើយដែលជាធម្មជាតិដឹកនាំទៅកាន់ការសម្រួះគ្នា ទៅដល់មិត្តភាព ទៅដល់ការចងបាច់គ្នា រួបរួមស្រុះស្រួលគ្នាហើយនឹងសន្តិភាព ។

ព្រះករុណា សូមថ្លែងនូវសេចក្ដីទំនុកទុកចិត្តដោយគោរព នឹងសេចក្ដីស្នេហាចំពោះទៅមន្ត្រីសង្ឃធំៗ នឹងវរសមណៈនោះនៃព្រះពុទ្ធសាសនាដ៏ថ្លៃថ្លាវិសេស របស់យើងគ្រប់ព្រះអង្គ ។ ចប់